00702724

E50/3/1/1/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour Suprême

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 06 / 06 / 2011
ម៉ោង (Time/Heure): 17:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

សំណុំរឿងលេខៈ ០០២/១៩-កញ្ញា-២០០៧-អ.វ.ត.ក/អ.ជ.ត.ក(០៤)
Case File/Dossier N°. 002/19-09-2007-ECCC/SC(04)

នៅចំពោះមុខៈ
ចៅក្រម គង់ ស្រីម ប្រធាន
ចៅក្រម Motoo NOGUCHI
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Agnieszka KLONOWIECKA-MILART
ចៅក្រម សុិន រិទ្ធ
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម យ៉ា ណារិន

កាលបរិច្ឆេទឯកសារៈ ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១១

សាធារណៈ / Public

ចំណាត់ថ្នាក់ឯកសារៈ សាធារណៈ

---

**សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់**

---

០០២/១៩-កញ្ញា-២០០៧-អ.វ.ត.ក/អ.ជ.ត.ក
ឯកសារលេខ E50/3/1/4

**<u>ជនជាប់ចោទ</u>**
ខៀវ សំផន

**<u>មេធាវីការពារក្តីជនជាប់ចោទ</u>**
**<u>ខៀវ សំផន</u>**
ស សុវាន
Jacques VERGÈS

**<u>សហព្រះរាជអាជ្ញា</u>**
ជា លាង
Andrew CAYLEY

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**
ពេជ អង្គ
Elisabeth SIMMONEAU-FORT

**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“**អ.វ.ត.ក**”) បានទទួលបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីសំណើសុំដោះលែងជនជាប់ចោទជាបន្ទាន់ ដែលបានដាក់ដោយសហមេធាវីការពារក្តីជនជាប់ចោទ **ខៀវ សំផន** (“**ជនជាប់ចោទ**”) ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំដោះលែងរបស់ជនជាប់ចោទ ។

## ១. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេត បានចេញដីកាដំណោះស្រាយរបស់ខ្លួនក្នុងសំណុំរឿងលេខ០០២/១៩-០៩-២០០៧/អ.វ.ត.ក(“សំណុំរឿង០០២”) ដោយធ្វើការបង្គាប់ថា ជនជាប់ចោទត្រូវរក្សាទុកក្នុងឃុំជាបណ្តោះអាសន្ន រហូតដល់ពេលនាំខ្លួនទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[1]។ អង្គបុរេជំនុំជម្រះ បានទទួលសំណុំរឿងបន្ទាប់ពីជនជាប់ចោទដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍[2] និងសារណាបណ្តឹងឧទ្ធរណ៍[3]ប្រឆាំងនឹងដីកាដំណោះស្រាយ (ដែលហៅថា “សារណាបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទប្រឆាំងនឹងដីកាដំណោះស្រាយ”)។

២. នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះ បានចេញសាលដីកាមិនទាន់មានសំអាងហេតុស្តីពីបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទប្រឆាំងនឹងដីកាដំណោះស្រាយ (“ផ្នែកសម្រេចសេចក្តី”) ដោយធ្វើការបញ្ជាក់ថា សំអាងហេតុនឹងចេញទៅតាមពេលវេលាសមស្រប[4]។ ផ្នែកសម្រេចសេចក្តី ធ្វើការសម្រេចថា បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទប្រឆាំងនឹងដីកាដំណោះស្រាយ មិនអាចទទួលយកបាន ហើយបង្គាប់ឲ្យរក្សាទុកជនជាប់ចោទក្នុងឃុំបណ្តោះអាសន្នរហូតដល់ពេលនាំខ្លួនទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[5]។ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ អង្គបុរេ

---

[1] D427 កថាខណ្ឌ១៦២២-១៦២៤ និងទំព័រ៤០២(“ដីកាដំណោះស្រាយ”)។ ដីកាដំណោះស្រាយ ត្រូវបានជូនដំណឹងដល់ភាគីនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០។

[2] សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ D427/4 ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១០។

[3] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ D427/4/3 នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១០។

[4] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផនប្រឆាំងនឹងដីកាដំណោះស្រាយ D427/4/14 ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១។

[5] សេចក្តីសម្រេច ទំព័រ៤។

ជំនុំជម្រះ បានចេញសំអាងហេតុពេញលេញលើផ្នែកសម្រេចសេចក្តី ដោយបង្គាប់ឲ្យរក្សាទុកជនជាប់ចោទក្នុងឃុំបណ្តោះអាសន្ន (“សាលដីកាដែលមានសំអាងហេតុពេញលេញ”)[6]។

៣. នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១១ ជនជាប់ចោទ បានដាក់សំណើសុំដោះលែងជាបន្ទាន់ទៅអង្គជំនុំជម្រះសាលាដំបូង[7] និងនៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសម្រេចរបស់ខ្លួនដោយបដិសេធសំណើនេះ (“សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង”)[8]។ នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១១ ជនជាប់ចោទ បានដាក់សារណាបណ្តឹងសាទុក្ខ (“បណ្តឹងសាទុក្ខ”)ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង[9] មកអង្គជំនុំជម្រះតុលាការកំពូល។ នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១១[10] សហព្រះរាជអាជ្ញា បានដាក់សារណាតបរបស់ខ្លួន (“សារណាតប”)។ បន្ទាប់មក ជនជាប់ចោទ បានដាក់ការឆ្លើយតបរបស់ខ្លួនទៅនឹងសារណាតប(“ការឆ្លើយតប”)នេះ នៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១[11]។

៤. អនុលោមតាមវិធាន១០៨(៤)នៃវិធានផ្ទៃក្នុង(វិសោធនកម្មលើកទី៧) អង្គជំនុំជម្រះតុលាការកំពូលត្រូវចេញសេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ជនជាប់ចោទឲ្យបានឆាប់ ដែលអាចធ្វើទៅបាន និងក្នុងគ្រប់ករណីទាំងអស់ ត្រូវសម្រេចក្នុងរយៈពេលមិនឲ្យលើសពីថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១១ ដែលជារយៈពេលបីខែប្រតិទិន គិតពីថ្ងៃជូនដំណឹងអំពីសារណាបណ្តឹងសាទុក្ខ[12]។

---

[6] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ខៀវ សំផនប្រឆាំងនឹងដីកាដំណោះស្រាយ D427/4/15 ថ្ងៃទី២១ ខែមករា ឆ្នាំ២០១១។

[7] សំណើសុំដោះលែងឲ្យមានសេរីភាព យោងតាមវិធាន៨២(៣)នៃវិធានផ្ទៃក្នុង E18 នៅថ្ងៃទី១៨ មករា ឆ្នាំ២០១១។

[8] សេចក្តីសម្រេចស្តីពីសំណើសុំដោះលែងជាបន្ទាន់របស់ នួន ជា ខៀវ សំផន និងអៀង ធីរិទ្ធ, E50,ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១។

[9] បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចលើសំណើសុំឲ្យដោះលែងជាបន្ទាន់ E50/3 នៅថ្ងៃទី៣ មីនា ឆ្នាំ២០១១។

[10] សារណាតបរបស់ព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចលើសំណើសុំដោះលែងជាបន្ទាន់ E50/3/1/1 ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១១។

[11] ការឆ្លើយតប E50/3/1/3 នៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១។

[12] វិធាន១០៨(៤)នៃវិធានផ្ទៃក្នុង។ ដោយសារវិធាន១០៥(២)មិនបានតម្រូវឲ្យមានសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ផ្ទុយទៅនឹងវិធាន១០៥(៣)នៃវិធានផ្ទៃក្នុង ពាក្យ“សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ” ក្នុងវិធាន១០៨(៤)នៃវិធានផ្ទៃក្នុង គឺសំដៅទៅលើ“បណ្តឹងសាទុក្ខដែលរៀបរាប់អំពីទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខ និងការលើកឡើងដើម្បីគាំទ្រ” នៅក្នុងវិធាន១០៥(២) ដែលជាសារណាបណ្តឹងសាទុក្ខ។ ក្នុងឯកសារខ្មែរនៃវិធាន១០៨(៤)នៃផ្ទៃក្នុង កាលបរិច្ឆេទរយៈពេលកំណត់បីខែ ត្រូវគិត

00702728



## ២. សារណា

### ២.១ ចំណុចបណ្តឹងសាទុក្ខរបស់ ខៀវ សំផន

៥. ជនជាប់ចោទ បានលើកទឡ្ហីករណ៍ចំនួនបីនៅក្នុងសារណាបណ្តឹងសាទុក្ខដូចខាងក្រោមៈ

#### ២.១.១ ការគាំទ្រចំពោះការបកស្រាយវិធាន៦៨(៣)នៃវិធានផ្ទៃក្នុង

៦. ជនជាប់ចោទ លើកឡើងថា ("រយៈពេល៤(បួន)ខែ") នៅក្នុងវិធាន៦៨(៣)នៃវិធានផ្ទៃក្នុង ត្រូវគិតចាប់ពីថ្ងៃជូនដំណឹងនៃដីកាដំណោះស្រាយ ហើយថា ការបកស្រាយនេះ ត្រូវបានពង្រឹងបន្ថែមតាមការអានបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ហើយដែល សហព្រះរាជអាជ្ញាក៏យល់ស្របតាមដែរ។ ប្រសិនបើ នៅតែមានមន្ទិលសង្ស័យស្តីពីកាលបរិច្ឆេទនៃការចាប់ផ្តើមគិត ភាពមន្ទិលសង្ស័យនេះ គួរតែបកស្រាយក្នុងន័យជាប្រយោជន៍ដល់ជនជាប់ចោទ[13]។

៧. សារណារបស់ជនជាប់ចោទលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង បានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយវាយតម្លៃថា ការរក្សាទុកជនជាប់ចោទក្នុងឃុំរបស់សហចៅក្រមស៊ើបអង្កេត ស្របតាមវិធាន៦៨(៣)នៃវិធានផ្ទៃក្នុង ត្រូវចាប់ផ្តើមគិតពីថ្ងៃដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿង[14]។ វិធាន៦៨ មិនមានចែងការបញ្ជូនសំណុំរឿងទៅជំនុំជម្រះនៅអង្គជំនុំជម្រះសាលាដំបូងសោះ ហើយរឹតតែមិនលើកឡើងពីថិរវេលាបួនខែនោះទៅទៀត[15]។ ចំណុចចាប់ផ្តើមថិរវេលាបួនខែ គឺនៅថ្ងៃពេលជូនដំណឹងអំពីដីកាដំណោះស្រាយ (ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០) ហើយពុំមែននៅថ្ងៃបញ្ជូនសំណុំរឿងទៅជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង(ថ្ងៃទី១៤ ខែមករា ឆ្នាំ

---

ចាប់ពីថ្ងៃទទួលបាន "សំណុំរឿង"។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា"រយៈពេលបីខែ" ក្នុងវិធាន១០៨(៤) គឺចាប់ផ្តើមគិតពីពេលជូនដំណឹងនៃសារណាបណ្តឹងសាទុក្ខ នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១១។ រយៈពេលបីខែបន្ទាប់ពីថ្ងៃទី៤ ខែមីនា ឆ្នាំ២០១១ គឺនៅថ្ងៃសៅរ៍ ទី៤ ខែមិថុនា ឆ្នាំ២០១១។ អនុលោមតាមវិធាន៣៩(៣)នៃវិធានផ្ទៃក្នុង ដោយសាររយៈពេលកំណត់នេះ ផុតនៅថ្ងៃសៅរ៍ ដូច្នេះកាលបរិច្ឆេទរយៈពេលកំណត់ ជាស្វ័យប្រវត្តិបន្តនៅថ្ងៃបន្ទាប់ដែលជាថ្ងៃធ្វើការ ត្រូវនឹងថ្ងៃច័ន្ទ ទី៦ ខែមិថុនា ឆ្នាំ២០១១។

[13] សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ៨ អាស្រ័យលើវិធាន២១នៃវិធានផ្ទៃក្នុង។

[14] សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ១២។

[15] សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ១៤។

២០១១)នោះឡើយ។ អង្គជំនុំជម្រះសាលាដំបូង តម្រូវឱ្យនាំខ្លួន ខៀវ សំផន ទៅចំពោះមុខត្រឹមថ្ងៃទី១៦ ខែមករា ឆ្នាំ២០១១ ដែលជាថ្ងៃផុតកំណត់ថិរវេលានៃការឃុំខ្លួន ប៉ុន្តែអង្គជំនុំជម្រះ ខកខានមិនបានធ្វើដូច្នេះ ដោយសារតែការមិនផ្ចិតផ្ចង់ក្នុងការងាររបស់ខ្លួន[16]។

## ២.១.២ ការពន្យល់ហេតុផលដោយគាន់ច្រឡំអំពីការរក្សាទុកក្នុងឃុំបណ្តោះអាសន្ន

៨. អង្គជំនុំជម្រះសាលាដំបូង ប្រព្រឹត្តកំហុសឆ្គងផ្នែកអង្គច្បាប់ដោយបង្គាប់ឱ្យរក្សាទុកជនជាប់ចោទក្នុងឃុំបណ្តោះអាសន្នដោយផ្អែកតែចេតនារត់គេចខ្លួន ដោយសារតែជនជាប់ចោទប្រឈមមុខនឹងការផ្តន្ទាទោសធ្ងន់ធ្ងរ ប្រសិនបើតុលាការរកឃើញថាគាត់មានពិរុទ្ធ។ ដោយពិចារណាលើគោលការណ៍សន្មត់ទុកជាមុនថាគ្មានទោស ទំរង់នៃទោសទណ្ឌនេះ មិនគ្រប់គ្រាន់ទេ សម្រាប់យកមកធ្វើជាមូលហេតុក្នុងការបដិសេធការដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន[17]។ កំហុសឆ្គងរបស់អង្គជំនុំជម្រះនេះ នាំឱ្យបាត់សុពលភាពដល់សេចក្តីសម្រេច ហើយជនជាប់ចោទ គួរត្រូវបានដោះលែងដោយសារពុំមានលក្ខណៈវិនិច្ឆ័យផ្សេង ដែលបញ្ជាក់ការរក្សាទុកជនជាប់ចោទក្នុងឃុំថាត្រឹមត្រូវក្រៅពីពាក្យពេចន៍ដែលមានចែងនៅក្នុងវិធាន៦៣(៣)(ខ)(៣)នៃវិធានផ្ទៃក្នុង ឡើយ[18]។

## ២.១.៣ ការរំលោភលើសិទ្ធិទទួលបានការកាត់សេចក្តីប្រកបដោយយុត្តិធម៌

៩. ក្នុងអំឡុងពេលសវនាការដែលអង្គជំនុំជម្រះសាលាដំបូងធ្វើឡើងនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូង បានអញ្ជើញជនជាប់ចោទ និងសហព្រះរាជអាជ្ញាដើម្បីលើកឡើងថាតើភាគីបានពិចារណាលើលក្ខខណ្ឌដែលមានចែងក្នុងវិធាន៦៣(៣)នៃវិធានផ្ទៃក្នុង ស្តីអំពីការរក្សាទុកជនជាប់ចោទក្នុងឃុំបណ្តោះអាសន្ន ហើយថាតើ មានការផ្លាស់ប្តូរនូវកាលៈទេសៈទាក់ទងទៅនឹងជនជាប់ចោទទាំងបីដែរឬទេ។ ជនជាប់ចោទលើកឡើងថា សិទ្ធិទទួលបានពេលវេលាគ្រប់គ្រាន់សម្រាប់ត្រៀមការពារខ្លួន ត្រូវបានអង្គជំនុំជម្រះសាលាដំបូងរំលោភបំពានដោយមិនបានជូនដំណឹង

---

[16] សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ១៥។

[17] សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ១៧-២៣។

[18] សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ២៣។

ដល់ជនជាប់ចោទឲ្យលើកឡើងពីទឡ្ហីករណ៍ស្តីពីលក្ខខណ្ឌដែលមានចែងក្នុងវិធាន៦៣(៣) នៃវិធានផ្ទៃក្នុង[19]។ ជនជាប់ចោទ លើកឡើងថា "ប្រសិនបើអង្គជំនុំជម្រះ យ៉ាងហោចណាស់ បានផ្តល់នូវព័ត៌មានដល់ក្រុមមេធាវីជាមុនថា បញ្ហានេះ ត្រូវលើកយកទៅនិយាយនៅក្នុងសវនាការនោះ ក្រុមមេធាវីការពារក្តី អាចនឹងពង្រឹង និងពង្រីកអំណះអំណាងរបស់ខ្លួននៅក្នុងសវនាការ"[20]។ ជនជាប់ចោទ បដិសេធ"ការជួសជុលដែលអាចធ្វើទៅបាន" ដែលផ្តល់ដោយអង្គជំនុំជម្រះសាលាដំបូងនោះថាមិនគ្រប់គ្រាន់ឡើយ[21]។

១០. ជនជាប់ចោទលើកឡើងផងដែរថា អង្គជំនុំជម្រះសាលាដំបូង ប្រព្រឹត្តកំហុសឆ្គងផ្នែកអង្គច្បាប់ចំនួនពីរ ដោយខកខានមិនបានដោះស្រាយទឡ្ហីករណ៍របស់ជនជាប់ចោទ ស្តីពីបញ្ហាការត្រួតពិនិត្យតាមផ្លូវតុលាការនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន[22]។ ទីមួយ អង្គជំនុំជម្រះសាលាដំបូង ប្រព្រឹត្តកំហុសឆ្គង ដោយខកខាន មិនបានផ្តល់នូវទម្ងន់គ្រប់គ្រាន់ទៅលើទឡ្ហីករណ៍របស់ជនជាប់ចោទទាក់ទងនឹងការត្រួតពិនិត្យតាមផ្លូវតុលាការ ហើយ ដូច្នេះ ខកខានមិនបានផ្តល់មូលហេតុក្នុងសេចក្តីសម្រេចរបស់ខ្លួន។ ទីពីរ នៅពេលដែលវិធាន៨២(២)នៃវិធានផ្ទៃក្នុង តម្រូវឲ្យអង្គជំនុំជម្រះសាលាដំបូង សម្រេចសេចក្តីលើបញ្ហានៃការត្រួតពិនិត្យតាមផ្លូវតុលាការនោះ អង្គជំនុំជម្រះសាលាដំបូង ប្រាកដជាបានមើលរំលងទាំងស្រុងនូវលទ្ធភាពក្នុងការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[23]។ ហេតុដូច្នេះ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ពុំមានសុពលភាពដោយមានការភាន់ច្រឡំផ្នែកអង្គច្បាប់ ដោយសារការរក្សាទុកជនជាប់ចោទក្នុងឃុំបណ្តោះអាសន្ន មិនមានមូលហេតុត្រឹមត្រូវដោយកង្វះនូវលក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការ

---

[19] សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ២៥-២៦។

[20] សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ២៦។

[21] សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ២៧ យោងទៅលើសេចក្តីថ្លែងការណ៍របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងកថាខណ្ឌ៤២នៃសេចក្តីសម្រេចរបស់ខ្លួនដែលថា អង្គជំនុំជម្រះ មិនបានតម្រូវឲ្យជនជាប់ចោទបង្ហាញនូវការប្រែប្រួលស្ថានភាព ប្រសិនបើមានសំណើថ្មីដោយអនុលោមតាមវិធាន៨២នៃវិធានផ្ទៃក្នុង។

[22] សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ២៨។

[23] សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ៣១-៣៤។

ដោយហេតុថាទោះក្នុងករណីណាក៏ដោយ ការត្រួតពិនិត្យតាមផ្លូវតុលាការត្រូវតែជានាវត្តមានរបស់ជនជាប់ចោទក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី[24]។

១១. ជនជាប់ចោទស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលៈ

ក. បដិសេធសេចក្តីសម្រេចដែលបានតវ៉ារបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងផ្នែកសម្រេចសេចក្តីដែលបានតវ៉ានោះ

ខ. បង្គាប់ឱ្យដោះលែង ខៀវ សំផន ជាបន្ទាន់ និង

គ. ព្រមទទួលថា ខៀវ សំផន ទទួលរងការរំលោភលើសិទ្ធិទទួលបាននូវការកាត់សេចក្តីប្រកបដោយយុត្តិធម៌ និងមានព្យសនកម្មធ្ងន់ធ្ងរ។

## ២.២ សារណាតបរបស់សហព្រះរាជអាជ្ញា

១២. សហព្រះរាជអាជ្ញា បានឆ្លើយតបទៅនឹងសារណារបស់ជនជាប់ចោទជាមួយទឡ្ហីករណ៍ដូចខាងក្រោមៈ

### ២.២.១ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការសន្និដ្ឋានយ៉ាងត្រឹមត្រូវថាវិធាន៦៨ផ្តល់សិទ្ធិរយៈពេលបួនខែចំនួនពីរដងខុសគ្នា

១៣. សហព្រះរាជអាជ្ញាលើកឡើងថា វិធាន៦៨(៣)នៃវិធានផ្ទៃក្នុង ចែងអំពីលទ្ធភាពនៃរយៈពេលឃុំខ្លួនបួនខែចំនួនពីរដងៈ ដែលលើកទីមួយអាចត្រូវបានបង្គាប់ដោយ ស.ច.ស នៅក្នុងដីកាដំណោះស្រាយ និងលើកទីពីរ អាចនឹងបង្គាប់ដោយអង្គបុរេជំនុំជម្រះក្នុងករណីមានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ[25]។ ការជំទាស់តវ៉ារបស់ជនជាប់ចោទដែលថាសហព្រះរាជអាជ្ញាបានលើកឡើងដែលថា មានតែរយៈពេលបួនខែតែម្តងប៉ុណ្ណោះនោះ គឺជាការយល់ខុសដោយ

---

[24] សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ៣៨។

[25] សារណាតប កថាខណ្ឌ៩។

សារតែសារណាដែលយោងនោះគឺដោះស្រាយតែលើទឡ្ហីករណ៍របស់ នួន ជា ដែលថាការឃុំខ្លួនកម្រិតត្រឹមតែរយៈពេលបីឆ្នាំ[26]។

## ២.២.២ ការឃុំខ្លួនជនជាប់ចោទបានបន្តតាមវិធាន៨២(១)

១៤. សហព្រះរាជអាជ្ញាលើកឡើងថា ដោយសារថាការឃុំខ្លួនជនជាប់ចោទត្រូវបាន អ.ប.ជ ធ្វើការបន្តដែលប្រកបដោយសុពលភាព ហើយជនជាប់ចោទត្រូវបាននាំទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ក្នុងរយៈពេលបួនខែនៃសេចក្តីសម្រេចនេះ ការឃុំខ្លួនរបស់គាត់គឺត្រូវបន្តដោយស្វ័យប្រវត្តិដោយអនុលោមតាមអនុវិធាន៨២(១)[27]។ ដោយធ្វើការប្រៀបធៀបជាមួយលក្ខខណ្ឌក្នុងការរក្សាទុកក្នុងឃុំដោយអនុលោមតាមវិធាន៦៣នៃវិធានផ្ទៃក្នុង ដែលជនត្រូវចោទ កំពុងស្ថិតក្រោមការស៊ើបអង្កេត ហើយនិងការសំអាងលើវិធាននៃនីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់អតីតយូហ្គោស្លាវី និងរ៉ូហ្វាន់ដា និងតុលាការពិសេសសំរាប់សេរ៉ាឡេអូន សហព្រះរាជអាជ្ញាលើកឡើងថា វិធាន៨២នៃវិធានផ្ទៃក្នុង បានប្តូរយ៉ាងមានប្រសិទ្ធភាពនូវការសន្មត់ទុកជាមុនទាក់ទងទៅនឹងការឃុំខ្លួន ពីពេលដែលអង្គជំនុំជម្រះសាលាដំបូង បានចាប់ដំណើរការសំណុំរឿង[28]។ ដោយសារតែអង្គជំនុំជម្រះសាលាដំបូង បដិសេធនូវសំណើសុំរបស់ជនជាប់ចោទដែលសំអាងលើតែទឡ្ហីករណ៍ដែលថា ការឃុំខ្លួនគាត់គឺកន្លងផុតហួសហើយ ការឃុំខ្លួនរបស់ជនជាប់ចោទ ត្រូវធ្វើបន្តទៀតជាស្វ័យប្រវត្តិ។ ដោយសារតែអង្គជំនុំជម្រះសាលាដំបូង មិនឋិតនៅក្រោមកាតព្វកិច្ចណាមួយដើម្បីធ្វើការពិចារណាលើកត្តានានានៅក្នុងវិធាន៦៣(៣)នៃវិធានផ្ទៃក្នុង ទើបជនជាប់ចោទ ត្រូវរក្សាទុកក្នុងឃុំដោយសុពលភាព[29]។

## ២.២.៣ ការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូងលើកត្តានានានៃអនុវិធាន ៦៣(៣)មិនបានធ្វើឲ្យការរក្សាទុកជនជាប់ចោទក្នុងឃុំអស់សុពលភាព

[26] សារណាតប កថាខណ្ឌ១០។

[27] សារណាតប កថាខណ្ឌ១១។

[28] សារណាតប កថាខណ្ឌ១៣។

[29] សារណាតប កថាខណ្ឌ១៤។

00702733



១៥. សហព្រះរាជអាជ្ញាព្រមទទួលថា មូលហេតុនានាដែលអង្គជំនុំជម្រះសាលាដំបូងបានផ្តល់ ដូចជាអង្គហេតុដែលថា ជនជាប់ចោទត្រូវបានបញ្ជូនទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរនោះ មិនបានផ្តល់យុត្តិកម្មលើការរកឃើញមួយដែលថាការរក្សាទុកក្នុងឃុំបណ្តោះអាសន្ន គឺជាការចាំបាច់ដើម្បីធានាអំពីវត្តមានរបស់គាត់នៅក្នុងអំឡុងពេលនៃដំណើរការនីតិវិធី[30]។ ប៉ុន្តែ សហព្រះរាជអាជ្ញាលើកឡើងថា ការខកខាននេះ គួរតែយល់នៅក្នុងបរិបទដែលជនជាប់ចោទ មិនបានធ្វើសំណើសុំដោះលែងដោយឈរលើមូលដ្ឋាននៃវិធាន៦៣(៣)នៃវិធានផ្ទៃក្នុងនោះទេ និងថា អង្គជំនុំជម្រះសាលាដំបូងបានអញ្ជើញឱ្យភាគីធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់លើវិធាន៦៣(៣)នៃវិធានផ្ទៃក្នុងនៅពេលសវនាការបុណ្ណោះ និងថា អង្គជំនុំជម្រះសាលាដំបូង បានកត់សំគាល់ថា មូលដ្ឋានដ៏ត្រឹមត្រូវសម្រាប់ការរក្សាទុកជនជាប់ចោទក្នុងឃុំតាមវិធាន៨២(១)នៃវិធានផ្ទៃក្នុង[31]។ អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់ថា បើភាគីមានបំណងធ្វើសំណើសុំដោះលែងណាមួយនាពេលអនាគត អ្នកទាំងនេះ មិនតម្រូវឱ្យបង្ហាញពីការផ្លាស់ប្តូរកាលៈទេសៈណាមួយឡើយ។ ដូចនេះ វាមិនបានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទឡើយ ក្នុងការធ្វើសំណើសុំដោះលែងមួយដែលមានមូលដ្ឋាននៅលើលក្ខណៈវិនិច្ឆ័យនៅក្នុងការអនុវត្តវិធាន៦៣(៣)នៃវិធានផ្ទៃក្នុង។ ដូច្នេះ គឺបានធានាថា គ្មានភាពលំអៀងដាក់ទៅខាងជនជាប់ចោទឡើយ[32]។

### ២.២.៤ លក្ខខណ្ឌសំខាន់ៗសម្រាប់រក្សាទុកជនជាប់ចោទក្នុងឃុំត្រូវបានបំពេញដោយអនុលោមតាមវិធាន៦៣(៣)នៃវិធានផ្ទៃក្នុង

១៦. សហព្រះរាជអាជ្ញាលើកឡើងថា គឺឋិតនៅលើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ តុលាការកំពូលក្នុងការដឹកនាំធ្វើការពិនិត្យសារជាថ្មីឡើងវិញនូវអង្គហេតុនានា ហើយនិង ឬមួយក៏គាំទ្រ ឬមួយក៏ធ្វើវិសោធនកម្មលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយរួមទាំងការបញ្ចូលនូវការពិចារណារកហេតុផលរបស់ខ្លួនផ្ទាល់[33]។ សហព្រះរាជអាជ្ញាលើកឡើងថា ការរក្សាទុកជនជាប់ចោទក្នុងឃុំ ត្រូវបានធ្វើយុត្តិកម្មតាមវិធាន៦៣(៣)(ខ)(៤)និង(៥) ដោយសំអាងថាជា

[30] សារណាតប កថាខណ្ឌ១៦។

[31] សារណាតប កថាខណ្ឌ១៧។

[32] សារណាតប កថាខណ្ឌ១៨។

[33] សារណាតប កថាខណ្ឌ៥, ៦និង១៩។

ការការពារសុវត្ថិភាពរបស់ជនជាប់ចោទ និងរក្សាសណ្តាប់ធ្នាប់សាធារណៈ[34]។ សហព្រះរាជអាជ្ញា បានរៀបរាប់នូវភស្តុតាងផ្សេងៗក្នុងការធ្វើយុត្តិកម្មលើអំណះអំណាងរបស់ខ្លួន ទាក់ទងនឹងការសំអាងទាំងនេះ[35]។

### ២.២.៥ អង្គជំនុំជម្រះសាលាដំបូង មិនបានរំលោភទៅលើសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌

១៧. សហព្រះរាជអាជ្ញា លើកឡើងថា ទឡ្ហីករណ៍របស់ជនជាប់ចោទទាក់ទងនឹងការបំពានលើសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌ មិនមានមូលដ្ឋានឡើយ ដោយសារតែ ទឡ្ហីករណ៍នេះ សំអាងតែលើពាក្យសុំដោះលែងមួយដែលមានហេតុផលត្រឹមត្រូវ ដោយអនុលោមតាមវិធាន៨២(២)នៃវិធានផ្ទៃក្នុងប៉ុណ្ណោះ ដែលមានភស្តុតាងគាំទ្រ ដូចជាការជំនួសការរក្សាទុកក្នុងឃុំណាមួយដែលអាចមាន ដែលគេរំពឹងទុកថា អង្គជំនុំជម្រះ នឹងពិចារណាចំពោះការជំនួសដ៏ជាក់លាក់ណាមួយ ដូចជាការត្រួតពិនិត្យតាមផ្លូវតុលាការជាដើម[36]។

### ២.៣ ការឆ្លើយតបរបស់ ខៀវ សំផន ទៅនឹងសារណាតបរបស់សហព្រះរាជអាជ្ញា

---

[34] សារណាតប កថាខណ្ឌ២៣។

[35] សំរាប់ហានិភ័យដល់សន្តិសុខរបស់ជនជាប់ចោទ, សូមមើលសារណាតប កថាខណ្ឌ២៤-២៦, (រំលឹកឡើងវិញថា ជនជាប់ចោទ ស្ទើរតែត្រូវបានសម្លាប់នៅពេលដែលជនជាប់ចោទ ត្រឡប់មកទីក្រុងភ្នំពេញ នៅក្នុងឆ្នាំ១៩៩១ , ដែលជនជាប់ចោទ បានបង្ហាញមុខនៅក្នុងវេទិកាសាធារណៈក្នុងឆ្នាំ២០០០ ជាការធានានូវសុវត្ថិភាពរបស់ជនជាប់ចោទ និងអះអាងថា ប្រតិកម្មរបស់ជនរងគ្រោះ រួមមានការសងសឹក ដែលលេចចេញតាមសារព័ត៌មាន និងប្រតិចារឹកនៃសវនាការ បង្ហាញផងថា ប្រសិនបើដោះលែង សុវត្ថិភាពរបស់គាត់ ជួបហានិយភាពធ្ងន់ធ្ងរ), ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូល បន្ទាប់ពីបានពិនិត្យលើឯកសារយោងរបស់សហព្រះរាជអាជ្ញារួចមក កត់សំគាល់ឃើញថា ឯកសារទាំងនេះ មានលក្ខណៈមិនត្រឹមត្រូវទាំងស្រុង (ទំព័រដែលត្រឹមត្រូវនៃប្រតិចារឹកនៃដំណើរការនីតិវិធី ដកស្រង់នៅក្នុងសារណាតបជើងទំព័រ៣៨ ទំព័រ១០៨ និងសេចក្តីថ្លែងការណ៍ដែលបានដកស្រង់នៅក្នុងសារណាតប កថាខណ្ឌ២៧-២៨ មិនមាននៅក្នុងឯកសារណាមួយដែលរៀបរាប់ក្នុងតារាងសំអាងផ្លូវច្បាប់ E50/3/1/1.1)។ សំរាប់ហានិភ័យដល់សណ្តាប់ធ្នាប់សាធារណៈ មើលសារណាតប កថាខណ្ឌ២៧-២៨(យោងទៅលើស្ថានភាពសន្តិសុខមិនល្អជាទូទៅនៅក្នុងប្រទេសកម្ពុជា ដែលធ្វើឱ្យកាន់តែធ្ងន់ធ្ងរ ដោយសារការឈឺចាប់របស់ជនជាប់ចោទបណ្តាលមកពីការប៉ះទង្គិចផ្លូវចិត្តយ៉ាងខ្លាំង ដែលកាន់តែឈឺចាប់ខ្លាំងឡើងប្រសិនបើជនជាប់ចោទត្រូវបានដោះលែងនោះ)។

[36] សារណាតប កថាខណ្ឌ២៩-៣០, ផ្អែកលើសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំង[illegible] ពេលរក្សាទុកជនជាប់ចោទក្នុងឃុំបណ្តោះអាសន្ន (អង្គបុរេជំនុំជម្រះ) C26/9, ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០[illegible] កថាខណ្ឌ៣៤។

១៨. នៅក្នុងការឆ្លើយតបរបស់ខ្លួន ជនជាប់ចោទ ជាដំបូងលើកឡើងថា វិធាន១០៤ និង១០៥ ផ្តល់លទ្ធភាពដល់បណ្តឹងសាទុក្ខភ្លាមៗទាក់ទងនឹងកំហុសឆ្គងអង្គច្បាប់ ឬ អង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង។ ហេតុដូច្នេះ សារណាបណ្តឹងសាទុក្ខទាក់ទងនឹងកំហុសឆ្គងផ្នែកអង្គច្បាប់ មិនតម្រូវឲ្យបង្ហាញពីកំហុសឆ្គង ដែលស្តែងចេញពីការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដូចដែលសហព្រះរាជអាជ្ញាបានលើកឡើងនៅក្នុងសារណាតបរបស់ខ្លួនឡើយ[37]។ ជនជាប់ចោទលើកឡើងថា វិធាន១១០(១)នៃវិធានផ្ទៃក្នុង កម្រិតវិសាលភាពនៃបណ្តឹងសាទុក្ខត្រឹមបញ្ហាដែលបានលើកឡើងក្នុងសេចក្តីជូនដំណឹងប៉ុណ្ណោះ ហើយថា អង្គជំនុំជម្រះតុលាការកំពូលជៀសវាងបដិសេធដោយឥតគិតវែងឆ្ងាយនូវការយល់ឃើញរបស់ចៅក្រមសាលាដំបូង[38]។ បន្ថែមលើនេះ នៅក្នុងវិធាន៨២(១)និង(២)នៃវិធានផ្ទៃក្នុង ទាំងពីរនេះ បង្ហាញច្បាស់ណាស់ថា ពាក្យថា "ដោយអនុលោមតាមវិធានផ្ទៃក្នុងនេះ" គឺយោងទៅលើវិធាន៦៣(៣)(ខ)(៣) និងថា ការរក្សាទុកជនជាប់ចោទក្នុងឃុំ មិនអាចត្រូវបានបង្គាប់ជាស្វ័យប្រវត្តិ ដោយពុំមានលក្ខខណ្ឌច្បាស់លាស់កំណត់តាមច្បាប់បានឡើយ[39]។

## ៣. មូលដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខភ្លាមៗ

១៩. អនុលោមតាមវិធាន១០៤(១)និង១០៥(២)នៃវិធានផ្ទៃក្នុង បណ្តឹងសាទុក្ខភ្លាមៗ អាចផ្អែកលើមូលដ្ឋានមួយ ឬច្រើនដូចខាងក្រោម:

-កំហុសឆ្គងលើអង្គច្បាប់ ដែលនាំឲ្យមោឃៈ សេចក្តីសម្រេច

-កំហុសឆ្គងនៃអង្គហេតុ ដែលនាំឲ្យ មានភាពមិនយុត្តិធម៌

-កំហុសឆ្គង ដែលស្តែងចេញពីការប្រើឆន្ទានុសិទ្ធរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនាំឲ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ។

---

[37] ការឆ្លើយតប កថាខណ្ឌ៦-៧។

[38] ការឆ្លើយតប កថាខណ្ឌ១០-១២។

[39] ការឆ្លើយតប កថាខណ្ឌ១៦-១៧។

00702736



២០. នៅក្នុងសារណាតបទៅនឹងការទាមទាររបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងបទដ្ឋាននៃការពិនិត្យឡើងវិញ អង្គជំនុំជម្រះតុលាការកំពូល ធ្វើការបញ្ជាក់ថា ទឡ្ហីករណ៍បណ្តឹងសាទុក្ខដែលមានចែងក្នុងវិធាន១០៥(២)នៃវិធានផ្ទៃក្នុង ទាក់ទងនឹងបណ្តឹងសាទុក្ខភ្លាមៗ ត្រូវតែអានផ្តាច់ចេញពីគ្នា។ ហេតុដូច្នេះ ដើម្បីសំអាងលើទឡ្ហីករណ៍ទីមួយ ឬ ទីពីរនៃបណ្តឹងសាទុក្ខ (កំហុសឆ្គងនៃអង្គច្បាប់ ឬ អង្គហេតុ) ភាគីបណ្តឹងសាទុក្ខ មិនតម្រូវឲ្យបង្ហាញបន្ថែមនូវកំហុសឆ្គងដែលស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបណ្តាលឲ្យមានផលប៉ះពាល់ដល់សិទ្ធិរបស់ខ្លួនឡើយ។ វិធាន ១០៤(១)នៃវិធានផ្ទៃក្នុង"បន្ថែមពីនេះ បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង អាចធ្វើទៅបានដោយផ្អែកលើមូលដ្ឋាននៃការភ័ន្តច្រឡំដែលស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនាំអោយប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ"។ ឃ្លានេះ បង្កើតនូវទឡ្ហីករណ៍បន្ថែមមួយសម្រាប់បណ្តឹងសាទុក្ខភ្លាមៗ ដែលទឡ្ហីករណ៍នេះ មិនមែនសម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមឡើយ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ មិនមែនជាទឡ្ហីករណ៍តែមួយគត់សំរាប់បណ្តឹងសាទុក្ខភ្លាមៗនោះឡើយ។

## ៤. ផ្នែកសំអាងហេតុ

### ៤.១ ភាពត្រឹមត្រូវតាមទំរង់ច្បាប់

២១. អនុលោមតាមវិធាន១០៤(៤)(ខ)នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការរក្សាទុកជនជាប់ចោទក្នុងឃុំបណ្តោះអាសន្ន ដោយអនុលោមតាមវិធាន៨២នៃវិធានផ្ទៃក្នុង ត្រូវបើកផ្លូវឲ្យធ្វើបណ្តឹងសាទុក្ខភ្លាមៗមកអង្គជំនុំជម្រះតុលាការកំពូល។ ម្ចាស់បណ្តឹងសាទុក្ខ បានអនុវត្តតាមពេលវេលាកំណត់ ហេតុដូច្នេះ ទទួលយកបណ្តឹងសាទុក្ខ សារណាតប និងការឆ្លើយតបទុកជាត្រឹមត្រូវតាមទំរង់ច្បាប់[40]។

### ៤.២ ចំណុចចាប់ផ្តើមនៃរយៈពេលកំណត់បួនខែនៅក្នុងវិធាន៦៨(២)នៃវិធានផ្ទៃក្នុង

[40] ជនជាប់ចោទ ត្រូវបានអនុញ្ញាតពន្យារពេលដាក់ការឆ្លើយតបៈ សេចក្តីសម្រេចលើសំណើរបស់ខៀវសំផន [illegible] តបទៅនឹងសារណាតបរបស់សហព្រះរាជអាជ្ញា, E50/3/1/2/1 ថ្ងៃទី៧ ខែមេសា ឆ្នាំ២០១១។

២២. ដើម្បីកំណត់ថាតើសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះទាក់ទងនឹងការរក្សាទុកជនជាប់ចោទក្នុងឃុំបណ្ដោះអាសន្ន ត្រូវចេញក្នុងរយៈពេលកំណត់ដែលមានចែងក្នុងវិធានផ្ទៃក្នុង ដែរឬទេនោះ វាចាំបាច់ត្រូវកំណត់អំពីពេលប្រតិបត្តិការចាប់ផ្ដើម និងបញ្ចប់។ អង្គជំនុំជម្រះតុលាការកំពូលកត់សំគាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង បានផ្ដល់សំអាងហេតុខុសលើបញ្ហានេះ ហើយនិងផ្ដោតទៅលើបញ្ហាថា តើសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលចេញផ្នែកសម្រេចសេចក្ដីដោយមិនទាន់មានសំអាងហេតុ និងចេញសំអាងហេតុតាមក្រោយ ជាការបង្កើតឲ្យមានការរំលោភផ្នែកនីតិវិធី ដែលប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទ ដែរឬទេ។ អង្គជំនុំជម្រះតុលាការកំពូល សង្កេតឃើញថា បញ្ហានេះ នឹងត្រូវលើកយកមកពិចារណា ល្គឹកណា បានបង្ហាញថាសេចក្ដីសម្រេចពាក់ព័ន្ធរួមទាំងសំអាងហេតុនៃសេចក្ដីសម្រេចនោះផង ត្រូវបានអង្គបុរេជំនុំជម្រះសម្រេចហួសពេលវេលាកំណត់ដែលត្រូវបានអនុញ្ញាតដោយវិធានផ្ទៃក្នុង។ ដោយផ្អែកតាមការបកស្រាយដ៏ត្រឹមត្រូវនៃវិធានផ្ទៃក្នុង ប្រសិនបើ ផ្នែកសម្រេចសេចក្ដី និងសំអាងហេតុ ត្រូវចេញក្នុងរយៈពេលកំណត់ដែលមានចែងក្នុងវិធានផ្ទៃក្នុងនោះ បញ្ហានៃការបំបែកនេះ ពុំមែនជាបញ្ហាចោទឡើយ។ ដូច្នេះ ដំបូង ជាការចាំបាច់ណាស់ ត្រូវសម្រេចថា តើសំអាងហេតុរបស់អង្គបុរេជំនុំជម្រះសំរាប់សំណុំរឿងនេះ ត្រូវបានអង្គបុរេជំនុំជម្រះ ចេញក្នុងរយៈពេលកំណត់ដែលបានអនុញ្ញាតសំរាប់អង្គបុរេជំនុំជម្រះចេញសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ជនជាប់ចោទប្រឆាំងនឹងដីកាដំណោះស្រាយ ឬទេ។

២៣. ហេតុដូច្នេះ ដើម្បីបដិសេធចោលនូវសំណើចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង គប្បីមានការចាប់ផ្ដើមកំណត់នូវការផុតកំណត់នៃកាលបរិច្ឆេទរយៈពេលបួនខែ នៅក្នុងវិធាន៦៨(២)នៃវិធានផ្ទៃក្នុង ជាពិសេស ដោយបកស្រាយអំពីភាពខ្វះចន្លោះនៃវិធានផ្ទៃក្នុង ទាក់ទងទៅនឹងចំណុចចាប់ផ្ដើមគិតនៃកាលបរិច្ឆេទនេះ។ បញ្ហានេះ ទាមទារឲ្យមានការបកស្រាយច្បាស់លាស់ ដោយហេតុថា មានហេតុផលមួយចំនួនស្ថិតនៅពីក្រោយអង្គបុរេជំនុំជម្រះ ដែលមានលក្ខណៈពិសេសក្នុងការជ្រើសរើស ដោយធ្វើការបំបែករវាងផ្នែកសម្រេចសេចក្ដី និងផ្នែកសំអាងហេតុ។ អង្គជំនុំជម្រះតុលាការកំពូល កត់សំគាល់ឃើញថា ជនជាប់ចោទអះអាងថា សេចក្ដីជូនដំណឹងអំពីដីកា

00702738



ដំណោះស្រាយ គឺជាចំណុចចាប់ផ្តើមគិតនៃរយៈពេលកំណត់[41]។ សហព្រះរាជអាជ្ញា មិនបាន លើកឡើងឲ្យបានជាក់លាក់លើចំណុចនេះទេ។

២៤. យោងតាមសំអាងហេតុដែលមាននៅក្នុងកថាខណ្ឌខាងក្រោម អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា ពេលកំណត់រយៈពេលបួនខែនៅក្នុងវិធាន៦៨(២)នៃវិធានផ្ទៃក្នុង ត្រូវផ្តើមគិតចាប់ពីថ្ងៃដាក់សារណាបណ្តឹងឧទ្ធរណ៍ផ្នែកខ្លឹមសារប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត។ ការអះអាងនេះ គឺអនុលោមតាមវិធាន៦៨(១)-(៣) នៃវិធានផ្ទៃក្នុងដែលចែងថា:

> ១.ការចេញដីកាដំណោះស្រាយមានអានុភាពបញ្ចប់ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន និងដីកាសម្រេចដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនៅពេលដែលរយៈពេលកំណត់នៅក្នុងការប្តឹងឧទ្ធរណ៍ត្រូវផុតរលត់។ ប៉ុន្តែនៅពេលដែលសហចៅក្រមស៊ើបអង្កេតយល់ឃើញថា លក្ខខណ្ឌទាំងឡាយសម្រាប់បង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន ឬ ឲ្យមានការត្រួតពិនិត្យតាមផ្លូវតុលាការក្រោមវិធាន ៦៣ និង ៦៥ នៅតែតម្រូវ សហចៅក្រមស៊ើបអង្កេតអាចសម្រេចបន្តឃុំជនជាប់ចោទបណ្តោះអាសន្នតទៅទៀត ឬ រក្សាលក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការចំពោះជនជាប់ចោទដដែល នៅក្នុងសេចក្តីសម្រេចមានសំអាងហេតុជាក់លាក់មួយដោយឡែកនៅក្នុងដីកាដំណោះស្រាយរហូតដល់ជនជាប់ចោទនេះត្រូវនាំខ្លួនទៅជំនុំជម្រះនៅអង្គជំនុំជម្រះសាលាដំបូង។
>
> ២. នៅពេលមានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ អានុភាពនៃសេចក្តីសម្រេចរក្សាជនជាប់ចោទនៅក្នុងឃុំបណ្តោះអាសន្ន ឬការដាក់អោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបន្តមានអានុភាពអនុវត្តរហូតមានសេចក្តីសម្រេចពីអង្គបុរេជំនុំជម្រះ ។អង្គបុរេជំនុំជម្រះត្រូវសម្រេចក្នុងអំឡុងពេល៤(បួន)ខែ ។
>
> ៣. ក្នុងករណីណាក៏ដោយ សេចក្តីសម្រេចរក្សាទុកជនជាប់ចោទនៅក្នុងឃុំបណ្តោះអាសន្ន ឬ

[41] សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ៨០: "[...] វិធាន៦៨(៣)ចែងយ៉ាងច្បាស់, សេចក្តីជូនដំណឹងអំពីដីកាដំណោះស្រាយ ជាការចាប់ផ្តើមនៃរយៈពេលកំណត់"និងកថាខណ្ឌ១៥០: "រយៈពេលបួនខែ ត្រូវចាប់ផ្តើមគិតបន្ទាប់ពីសេចក្តីជូនដំណឹងអំពីដីកាដំណោះស្រាយ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ [...] ដូច្នេះរយៈពេលនេះ ផុតកំណត់នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១១[...]"។

រក្សាលក្ខខណ្ឌ នៃការដាក់អោយនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរបស់សហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ ត្រូវអស់អានុភាពក្នុងរយៈពេល៤(បួន)ខែក្រោយលើកលែងតែជនជាប់ចោទត្រូវបាននាំខ្លួនទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេលនោះ ។

២៥. ដោយមិនមានពាក្យពេចន៍ច្បាស់លាស់នៅក្នុងវិធាន ៦៨(២) នៃវិធានផ្ទៃក្នុង កាលបរិច្ឆេទចាប់ផ្តើមគិតរយៈពេលកំណត់បួនខែ ត្រូវកំណត់តាមរយៈការវិភាគអំពីបរិបទជាប្រព័ន្ធ និងគោលបំណងនៃការកំណត់ពេលវេលា។ ពាក់ព័ន្ធនឹងខ្លឹមសារនៅក្នុងបរិបទទីមួយនេះ ឧបញ្ញត្តិក្នុងន័យបើកទូលាយ (នៅពេលដែលបណ្តឹងឧទ្ធរណ៍ ត្រូវបានធ្វើឡើងប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ) គឺជាសញ្ញាបង្ហាញដំបូងថា ការចាប់ផ្តើមនៃពេលវេលាកំណត់នៅក្នុងកថាខណ្ឌនេះ គឺគិតពីពេលដាក់បណ្តឹងឧទ្ធរណ៍ ប៉ុន្តែ មិនគិតពីពេលចេញដីកាដំណោះស្រាយឡើយ។ ហេតុដូច្នេះ ចំណុចចាប់ផ្តើមសម្រាប់រយៈពេលកំណត់នៅក្នុងវិធាន៦៨(២)នៃវិធានផ្ទៃក្នុង មិនអាចគិតនៅពេលដែលចេញដីកាដំណោះស្រាយដែលជាព្រឹត្តិការណ៍មួយដែលកើតមុនពេលធ្វើបណ្តឹងឧទ្ធរណ៍។ ទាក់ទងទៅនឹងគោលបំណងនៃរយៈពេលកំណត់បួនខែនៅក្នុងវិធាន៦៨(២)នៃវិធានផ្ទៃក្នុង គឺដើម្បីរារាំងការរក្សាទុកជនជាប់ចោទក្នុងឃុំហួសពេលកំណត់។ ហេតុដូច្នេះ នៅពេលដែលអង្គបុរេជំនុំជម្រះ សម្រេចរក្សាទុកជនជាប់ចោទក្នុងឃុំ អង្គបុរេជំនុំជម្រះ ត្រូវចេញសេចក្តីសម្រេចក្នុងរយៈពេលកំណត់នេះ។ ដូចគ្នាដែរ ពេលកំណត់នេះ មានគោលបំណងដើម្បីផ្តល់ឲ្យអង្គបុរេជំនុំជម្រះនូវពេលវេលាគ្រប់គ្រាន់សំរាប់ពិនិត្យលើសំណុំរឿង និងបញ្ចប់នូវសេចក្តីសម្រេចរបស់ខ្លួន។ មិនមានលក្ខណៈសមហេតុផលក្នុងការបកស្រាយថា "រយៈពេលបួន ខែ" ក្នុងវិធាន៦៨(២)នៃវិធានផ្ទៃក្នុង ត្រូវរាប់បញ្ចូលផងដែរនូវរយៈពេលដែលអង្គបុរេជំនុំជម្រះ មិនអាចធ្វើការពិចារណាលើបណ្តឹងឧទ្ធរណ៍ដែលមិនស្ថិតក្នុងការគ្រប់គ្រងរបស់ខ្លួន ដូចជាកង្វះការដឹងអំពីការដាក់បណ្តឹងឧទ្ធរណ៍ ឬ កង្វះការដឹងអំពីវិសាលភាពនៃបណ្តឹងឧទ្ធរណ៍។

២៦. មាននីតិវិធី និងទំរង់បែបបទនានាដែលមានចែងក្នុងវិធានផ្ទៃក្នុងបានកំណត់លក្ខខណ្ឌចំពោះលទ្ធភាពរបស់អង្គបុរេជំនុំជម្រះ ក្នុងការចាប់ផ្តើមកិច្ចការរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍នៅចំពោះមុខប្រកបដោយប្រសិទ្ធភាព។ វិធាន៧៧(២)នៃវិធានផ្ទៃក្នុងចែងថា បន្ទាប់ពីទទួលបាននូវសេចក្តីជូនដំណឹងនៃបណ្តឹងឧទ្ធរណ៍ ក្រឡាបញ្ជីនៃសហចៅក្រមស៊ើបអង្កេត ត្រូវបញ្ជូនសំណុំរឿង ឬឯកសារចម្លង ទៅឲ្យអង្គបុរេជំនុំជម្រះ ក្នុងរយៈពេលប្រាំថ្ងៃ។ វិធាន៧៥(១)និង(៣)នៃវិធាន

ផ្ទៃក្នុងចែងថា ម្ចាស់បណ្តឹងឧទ្ធរណ៍ មានរយៈពេលដប់ថ្ងៃដើម្បីដាក់សេចក្តីជូនដំណឹងនៃបណ្តឹងឧទ្ធរណ៍ និង៣០ថ្ងៃ ដើម្បីដាក់សារណានៃបណ្តឹងឧទ្ធរណ៍គិតចាប់ពីថ្ងៃទទួលបាននូវការជូនដំណឹងនៃសេចក្តីសម្រេច ឬ ដីកាដែលតវ៉ា។ ដោយស្របតាមហេតុផលសមស្រប ការកំណត់ពេលវេលាដូចដែលមានចែងខាងលើ មានភាពមិនសមហេតុផលទេក្នុងការចងភ្ជាប់នូវការចាប់ផ្តើមគិតនៃរយៈពេល"៤ខែ"នៅក្នុងវិធាន៦៨(២)នៃវិធានផ្ទៃក្នុង ទៅនឹងថ្ងៃដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍របស់ភាគីនោះឡើយ។ ខុសប្លែកពីសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខមកអង្គជំនុំជម្រះតុលាការកំពូលប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង[42] សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ គឺគ្រាន់តែជាការបង្ហាញឱ្យឃើញពីចេតនារបស់ភាគីក្នុងការធ្វើបណ្តឹងឧទ្ធរណ៍លើសេចក្តីសម្រេច ឬ ដីការបស់សហចៅក្រមស៊ើបអង្កេតប៉ុណ្ណោះ[43]។ ផ្ទុយទៅវិញ សារណាបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ " ត្រូវមានសំអាងហេតុ ផ្នែកអង្គហេតុ និងអង្គច្បាប់ដែលជាមូលដ្ឋានបណ្តឹងឧទ្ធរណ៍ រួមទាំងឯកសារគាំទ្រទាំងអស់"[44]។ ហេតុដូច្នេះ បន្ទាប់ពីទទួលបាននូវសារណាបណ្តឹងឧទ្ធរណ៍ពីភាគី និងសំណុំរឿងពីសហចៅក្រមស៊ើបអង្កេត ទើបអង្គបុរេជំនុំជម្រះអាចកំណត់ពីវិសាលភាពនៃការពិនិត្យដែលខ្លួនត្រូវធ្វើលើបណ្តឹងឧទ្ធរណ៍នោះបាន។

២៧. ហេតុផលដូចគ្នាសំរាប់ការគណនានៃពេលកំណត់ បានបង្ហាញពីភាពចាំបាច់ក្នុងការធានាបាននូវពេលវេលាសមហេតុផល សំរាប់ភាគីធ្វើសកម្មភាពបណ្តឹង ដោយពុំមានផលប៉ះពាល់ដល់ពេលវេលាដែលបានផ្តល់ឱ្យអង្គបុរេជំនុំជម្រះធ្វើការសម្រេចឡើយ។ ភាគីត្រូវដាក់សារណាបណ្តឹងឧទ្ធរណ៍ក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពីថ្ងៃជូនដំណឹងនៃសេចក្តីសម្រេច ឬ ដីកាដែលអាចតវ៉ាបាន។ នៅក្នុងករណីដែលម្ចាស់បណ្តឹងឧទ្ធរណ៍ដាក់សេចក្តីជូនដំណឹងបណ្តឹងឧទ្ធរណ៍របស់ខ្លួននៅថ្ងៃទីមួយក្នុងរយៈពេលដប់ថ្ងៃតាមវិធាន៧៥(១)នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះអាចរង់ចាំរហូតដល់២៩ថ្ងៃទៀតសំរាប់ទទួលយក "សំអាងហេតុផ្នែកអង្គហេតុ និងអង្គច្បាប់ដែលជាមូលដ្ឋាននៃបណ្តឹង

---

[42] វិធាន១០៥(៣)នៃវិធានផ្ទៃក្នុង។

[43] វិធាន៧៥នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះតុលាការកំពូល រំលឹកថា កិច្ចប្រជុំពេញអង្គ បានណែនាំជាពិសេសអំពីលក្ខខណ្ឌសំរាប់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខដែលត្រូវដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះ ដោយមានទស្សនៈទានលើភាពមិនមែនអូររបស់អង្គជំនុំជម្រះក្នុងកម្ពុជា។

[44] វិធាន៧៥(៤)។

00702741



ឧទ្ធរណ៍”។ អង្គបុរេជំនុំជម្រះ អាចនឹងរង់ចាំយូរជាងនេះទៅទៀត ប្រសិនបើអង្គបុរេជំនុំជម្រះអនុញ្ញាតការពន្យារពេលដាក់សារណាបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើកាលៈទេសៈពិសេស។ បញ្ញត្តិដ៏ទៃទៀតនៅក្នុងវិធានផ្ទៃក្នុងគាំទ្រការបកស្រាយដែលថា កាលបរិច្ឆេទចាប់ផ្តើមនៃរយៈពេល “បួនខែ”ក្នុងវិធាន៦៨(២)នៃវិធានផ្ទៃក្នុង មិនអាចចាប់ផ្តើមគិតនៅពេលណាមួយមុនពេលដាក់សារណាលើបណ្តឹងឧទ្ធរណ៍របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះឡើយ។ ជាពិសេស រយៈពេលបីខែដែលអង្គជំនុំជម្រះតុលាការកំពូល ត្រូវចេញសេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗស្តីពីការឃុំខ្លួន ត្រូវគិតចាប់ពីថ្ងៃជូនដំណឹងអំពីសារណាបណ្តឹងសាទុក្ខ[45]។

២៨. អង្គជំនុំជម្រះតុលាការកំពូល កត់សំគាល់ថា ការយល់ឃើញរបស់ខ្លួនអំពីការចាប់ផ្តើមគិតរយៈពេលកំណត់ ដូចមានចែងក្នុងវិធាន៦៨(២)នៃវិធានផ្ទៃក្នុង មិនដូចគ្នាទៅនឹងបញ្ញត្តិពាក់ព័ន្ធនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឡើយ ហេតុដូច្នេះ សំអាងរបស់ជនជាប់ចោទដែលផ្អែកលើមាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ[46] មិនមានន័យឡើយ។ ទោះបីជារយៈពេល “បួនខែ”មានចែងក្នុងមាត្រា២៤៩[47]នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ត្រូវគិតចាប់ពីពេលចេញដីកាដំណោះស្រាយក៏ដោយ ក៏ភាពពាក់ព័ន្ធនៃបទប្បញ្ញត្តិនេះ ក៏ដូចជាបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដទៃទៀតដែលគ្រប់គ្រងលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ[48] ត្រូវតែ

[45] សូមមើលការពន្យល់ក្នុងជើងទំព័រ១២ ខាងលើ។

[46] សូមមើលសារណាបណ្តឹងសាទុក្ខ កថាខណ្ឌ៧។

[47] មាត្រា ២៤៩ ក្រមនីតិវិធីព្រហ្មទណ្ឌចែងថា៖

ដីកាដំណោះស្រាយបញ្ចប់ការឃុំខ្លួនបណ្តោះអាសន្ន។ មាត្រា២៧៦ (ការដោះលែងជនត្រូវចោទ ដែលជាប់ឃុំឱ្យមានសេរីភាព) នៃក្រមនេះ ត្រូវយកមកអនុវត្ត។

ប៉ុន្តែតាមសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរអាចរក្សាជនត្រូវចោទ ឱ្យនៅជាប់ឃុំបណ្តោះអាសន្ន រហូតដល់ពេលចូលបង្ហាញខ្លួននៅមុខតុលាការ។ នៅក្នុងដីកានេះ ចៅក្រមស៊ើបសួរត្រូវយោងតាមលក្ខខណ្ឌ នៃមាត្រា២០៥ (សំអាងហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន)នៃក្រមនេះ។

សេចក្តីសម្រេចរក្សាជនត្រូវចោទក្នុងមន្ទីរឃុំឃាំងបណ្តោះអាសន្ន លែងមានសុពលភាពក្នុងរយៈពេល៤ខែ។ ប្រសិនបើជនត្រូវចោទមិនបានចូលទៅបង្ហាញខ្លួននៅមុខតុលាការក្នុងរយៈពេលបួនខែនេះទេនោះ ជនត្រូវចោទ ត្រូវបានដោះលែងពីការឃុំបណ្តោះអាសន្នឯកឯង។

[48] សូមមើលមាត្រា២៦៦-២៦៨។

មានការវាយតម្លៃលើគ្រប់ទិដ្ឋភាពដែលមានចែងក្នុងក្រមនេះ ។ ក្នុងន័យនេះ ភាពខុសគ្នាជាសារវន្ត ត្រូវតែយកមកពិចារណាការវាងគោលបំណង នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងវិធានផ្ទៃក្នុងចំពោះបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ដែលឆ្លុះបញ្ចាំងឲ្យឃើញពីលក្ខណៈពិសេសនៃ អ.វ.ត.ក ដោយមូលហេតុភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងភាពស្មុគស្មាញនៃការស៊ើបអង្កេត តម្រូវឲ្យមានការពិនិត្យពិច័យឲ្យបានម៉ត់ចត់នៅដំណាក់កាលបុរេជំនុំជម្រះលើបទចោទនានា និងតម្រូវឲ្យមានការផ្តល់ជំនួយយ៉ាងទូលំទូលាយសំរាប់ជនជាប់ចោទ។ ដូច្នេះ ក្រមនីតិវិធីព្រហ្មទណ្ឌ មិនបានប្រមើលមើលពីបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយដោយជនជាប់ចោទ ក្នុងន័យទូលាយដូចដែលវិធានផ្ទៃក្នុងកំណត់នោះទេ ។ នៅក្នុងវិធានផ្ទៃក្នុង ឧបាស្រ័យប្រឆាំងនឹងដីកាដំណោះស្រាយ ដោយជនជាប់ចោទ អាចត្រូវបានធ្វើឡើងដោយឯករាជ្យ ដោយផ្អែកលើមូលដ្ឋានយុត្តាធិការ និង/ឬ ផ្អែកលើមូលដ្ឋានដែលពាក់ព័ន្ធនឹងការរក្សាទុកក្នុងឃុំបណ្តោះអាសន្ន[49]។ ជាងនេះទៅទៀត យោងតាមការផ្តល់សិទ្ធិអំណាចក្នុងន័យចង្អៀត សំរាប់ធ្វើបណ្តឹងឧទ្ធរណ៍ រយៈពេលកំណត់សំរាប់កិច្ចការបណ្តឹងឧទ្ធរណ៍ ដែលចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ មានរយៈពេលខ្លីជាងសំរាប់ភាគី ពោលគឺ មានរយៈពេលប្រាំថ្ងៃប៉ុណ្ណោះ[50]។ ប៉ុន្តែ រយៈពេលកំណត់សំរាប់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ យោងតាមវិធានផ្ទៃក្នុង ត្រូវបានពន្យារបន្ថែមដោយមូលហេតុមានភាពស្មុគស្មាញដែលបានប៉ាន់ប្រមាណទុកនៃរឿងក្តីនៅចំពោះមុខអ.វ.ត.ក។ ទីបញ្ចប់ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ ទាមទារឲ្យមានការពិនិត្យជាថ្មីឡើងវិញ ខណៈដែលវិធានផ្ទៃក្នុងតម្រូវឲ្យបណ្តឹងឧទ្ធរណ៍ផ្តោតទៅលើការលើកបង្ហាញទឡ្ហីករណ៍អង្គហេតុ និងអង្គច្បាប់។ សរុបមក ក្រមនីតិវិធីព្រហ្មទណ្ឌ មិនបានផ្តល់នូវសេចក្តីណែនាំចំពោះបញ្ហានៅចំពោះមុខទេ ហើយដែលបទប្បញ្ញត្តិដែលពាក់ព័ន្ធទាំងនោះ មិនមានលក្ខណៈគ្រប់គ្រាន់សំរាប់បណ្តឹងឧទ្ធរណ៍ចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះ សំរាប់ឧក្រិដ្ឋកម្មអន្តរជាតិឡើយ។ ការគណនារយៈពេលកំណត់នៅក្នុងវិធាន៦៨(២)នៃវិធានផ្ទៃក្នុង ដែលត្រូវផ្តើមគិតចាប់ពីថ្ងៃដាក់សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ត្រូវយោងតាមលទ្ធ

[49] វិធាន៧៤(៣)(ក)និង(ច)នៃវិធានផ្ទៃក្នុង។ សូមមើលសំអាងហេតុរបស់អង្គបុរេជំនុំជម្រះនៅក្នុងសេចក្តីសម្រេចស្តីពីបណ្តឹងកថាខណ្ឌ១៤។

[50] មាត្រា ២៧០។ ក្នុងករណីលើកលែង អគ្គព្រះរាជអាជ្ញាមានតែរយៈពេលមួយខែក្នុងការធ្វើបណ្តឹងឧទ្ធ[illegible]ណ្ណោះ។

ផលសមស្របដែលកើតចេញពីការទទួលយកនូវការរៀបចំជាពិសេសដទៃទៀតរបស់អ.វ.ត.ក នៅក្នុងវិធានផ្ទៃក្នុង។

២៩. នៅក្នុងរឿងក្តីនេះ ដីកាដំណោះស្រាយ ត្រូវបានជូនដំណឹងនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ ខៀវ សំផន បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១០ និងដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១០។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល កំណត់ថា យោងតាមស្ថានភាពខាងលើ រយៈពេលកំណត់បួនខែដែលចែងក្នុងវិធាន៦៨(២) ត្រូវចាប់ផ្តើមគិតពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០១០។ ថ្ងៃចុងក្រោយដែលស្របតាមរយៈពេលកំណត់បួនខែ គឺនៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១។ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះចេញសំអាងហេតុសំរាប់សេចក្តីសម្រេចដែលនៅសេសសល់នៅក្នុងផ្នែកសម្រេចសេចក្តី។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល កំណត់ថា សេចក្តីសម្រេចអង្គបុរេជំនុំជម្រះដែលមានផ្នែកសម្រេចសេចក្តី និងផ្នែកសំអាងហេតុ បានធ្វើក្នុងរយៈពេលកំណត់ដែលមានចែងក្នុងវិធានផ្ទៃក្នុង។

៣០. ជនជាប់ចោទ បានសំអាងផងដែរលើវិធាន២១(១)នៃវិធានផ្ទៃក្នុង និងគោលការណ៍វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ[51]។ អង្គជំនុំជម្រះតុលាការកំពូល សម្រេចថា ការគណនារយៈពេលកំណត់ដោយផ្តើមគិតចាប់ពីថ្ងៃដាក់សារណាបណ្តឹងឧទ្ធរណ៍ មានលក្ខណៈស្របទៅនឹងគោលកាណ៍ដែលមានចែងក្នុងវិធាន២១(១)នៃវិធានផ្ទៃក្នុង ដែលកំណត់ថា វិធានផ្ទៃក្នុង ត្រូវតែបកស្រាយ ជាប្រយោជន៍ដល់ជនជាប់ចោទ។ ដើម្បីបញ្ជាក់អំពីភាពស្របគ្នានេះ ជាបឋម គោលការណ៍ដែលមានចែងក្នុងវិធាន២១(១)នៃវិធានផ្ទៃក្នុង តម្រូវឱ្យមានការបកស្រាយបែបនេះ។ ក្នុងន័យនេះ អង្គជំនុំជម្រះតុលាការកំពូល សម្រេចថា វិធាន២១(១)នៃវិធានផ្ទៃក្នុង ត្រូវតែអានក្នុងន័យថា ការបកស្រាយវិធានផ្ទៃក្នុង មិនត្រូវឱ្យមានការរំលោភលើប្រយោជន៍ណាមួយរបស់ជនជាប់ចោទ ដែលកើតចេញពីសិទ្ធិសារវន្ត ត្រូវបានធានានៅក្នុងលក្ខន្តិកៈ និងលិខិតុបករណ៍អន្តរជាតិនានាជាធរមាន មានដូចជា ការសន្មត់ទុកជាមុនថាគ្មានទោស សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ សិទ្ធិនៅស្ងៀមមិនឆ្លើយតប សិទ្ធិទទួលបានការការពារខ្លួន។ ដូច្នេះ

[51] សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១។

00702744



ក្នុងការបង្កើតអត្ថន័យគតិយុត្តនៃវិធានផ្ទៃក្នុង ស្ថាប័នមានសមត្ថកិច្ចបកស្រាយ គួរតែធ្វើឱ្យស្រប តាមវិធាននៃការបកស្រាយច្បាប់ ដោយពិចារណាលើគោលការណ៍ទូទៅទាំងអស់ ក្នុងចំណោម គោលការណ៍ផ្សេងៗ ដែលការពារសិទ្ធិរបស់ជនជាប់ចោទ ហើយជាលទ្ធផលចុងក្រោយ គួរតែ វាយតម្លៃនៅក្នុងក្របខណ្ឌនៃសិទ្ធិទាំងនោះ។ គោលបំណងនៃការបកស្រាយចេញពីវិធាន២១(១) មិនមានន័យថា វិធានផ្ទៃក្នុង ត្រូវតែបកស្រាយ ក្នុងន័យផ្តល់ផលប្រយោជន៍ដល់ជនជាប់ចោទ ដោយស្វ័យប្រវត្តិនៅក្នុងគ្រប់ស្ថានភាពជាក់លាក់ដែលកើតចេញពីការបកស្រាយនៃវិធានផ្ទៃក្នុង ឡើយ។

៣១. បញ្ហាដែលទាក់ទិននឹងវិធាន២១(១)នៃវិធានផ្ទៃក្នុង គឺជាសញ្ញាណនៃគោលការណ៍វិមតិសង្ស័យត្រូវ បានជាប្រយោជន៍ដល់ជនជាប់ចោទ[52]។ អង្គជំនុំជម្រះតុលាការកំពូល បញ្ជាក់យ៉ាងមុតមាំថា គោលការណ៍នេះដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ[53]នៃព្រះរាជាណាចក្រកម្ពុជា ហើយដែល កើតចេញពីគោលការណ៍ការសន្មត់ទុកជាមុនថាគ្មានទោស និងដែលមានចែងជាមូលដ្ឋានក្នុងប្រព័ន្ធ គតិយុត្តរបស់កម្ពុជាផងដែរនោះ មានមុខងារជាចំបងក្នុងការបង្ហាញឱ្យឃើញនូវការយល់ដឹងជា ស្វ័យប្រវត្តិ ក្នុងករណីដែលពុំមានភស្តុតាងលុបបំបាត់ភាពមន្ទិលសង្ស័យ។ ចំពោះគោលការណ៍ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ អាចអនុវត្តបានចំពោះស្ថានភាពលំបាក នៃអត្ថន័យច្បាប់ គោលការណ៍នេះ ត្រូវកម្រិតត្រឹមតែភាពមន្ទិលសង្ស័យដែលនៅតែមានក្រោយការ បកស្រាយ។ ហេតុដូច្នេះ គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ត្រូវតែអនុវត្តយ៉ាងត្រឹមត្រូវចំពោះភាពមន្ទិលសង្ស័យអំពីខ្លឹមសារនៃបទដ្ឋានគតិយុត្តដែលនៅតែមាន ក្រោយការអនុវត្តន៍នូវវិធាននៃការបកស្រាយតាមប្រព័ន្ធច្បាប់ស៊ីវិល ដោយធ្វើការពិចារណាលើ ពាក្យពេចន៍នៃបទប្បញ្ញត្តិ ការដាក់បញ្ចូលក្នុងប្រព័ន្ធ រួមមានការជាប់ទាក់ទិនទៅនឹងគោល ការណ៍សំខាន់ៗដែលជាមូលដ្ឋានគ្រឹះ និងគោលបំណងនៃគោលការណ៍នេះ។ ដូចនេះ តាមការ អនុវត្តជាក់ស្តែង គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ នឹងមិនមាន ភាពចាំបាច់ ក្នុងការដោះស្រាយទៅលើភាពខ្វះចន្លោះនៃច្បាប់ឡើយ ប៉ុន្តែ អាចនឹងដើរតួនាទីក្នុង ករណីដែលមានវិវាទបទដ្ឋានច្បាប់នានា។

[52] សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ៨។

[53] មាត្រា ៣៨នៃរដ្ឋធម្មនុញ្ញកម្ពុជា។

៣២. ទាក់ទិននឹងការគណនានៃរយៈពេលកំណត់ក្នុងវិធាន៦៨(២)នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូល កត់សំគាល់ឃើញថា បញ្ហាចោទ គឺមិនមែនជាបញ្ហាស្តីពីសិទ្ធិសារវន្តរបស់ជនជាប់ចោទនោះទេ។ ប៉ុន្តែ ជាបញ្ហាបច្ចេកទេសនៃការបកស្រាយលក្ខន្តិកៈដែលមិនពាក់ព័ន្ធនឹងការប្រើប្រាស់សិទ្ធជាសារវន្តរបស់ជនជាប់ចោទឡើយ។ ដូច្នេះ គឺជាបញ្ហាបច្ចេកទេសមួយដែលតម្រូវឲ្យមានការឆ្លើយតបតាមលក្ខណៈបច្ចេកទេសវិញ ដែលជាលទ្ធផលធ្វើការថ្លឹងថ្លែងផលប្រយោជន៍ផ្សេងៗនៅក្នុងដំណើរនីតិវិធី។ ផលប្រយោជន៍របស់ជនជាប់ចោទ ត្រូវតែមានពេលវេលាគ្រប់គ្រាន់សំរាប់ត្រៀមរៀបចំបណ្តឹងឧទ្ធរណ៍ និងតុលាការក៏ត្រូវមានពេលវេលាគ្រប់គ្រាន់ឲ្យតុលាការដើម្បីធ្វើការពិចារណាលើបណ្តឹងឧទ្ធរណ៍ដែរ ដូច្នេះ ជាការពង្រឹងនូវការធានាថា បទចោទប្រកាន់នានាដែលមិនមានមូលដ្ឋានគ្រប់គ្រាន់ នឹងមិនត្រូវបានបញ្ជូនទៅជំនុំជម្រះបានឡើយ។ ជម្រើសក្នុងការដាក់បណ្តឹងឧទ្ធរណ៍ និងការប្រើប្រាស់ពេលវេលាកំណត់សំរាប់ជនជាប់ចោទ គឺជាការសម្រេចចិត្តដោយស្វ័យភាពរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍។ ផលប្រយោជន៍នេះ ត្រូវបានបំពេញទោះបីជាមានការពន្យារកិច្ចដំណើការនីតិវិធី ដែលរួមមានសេចក្តីសម្រេចបង្គាប់ឲ្យឃុំខ្លួន ហើយចេះតែដើរទៅមុខផ្ទុយទៅនឹងប្រយោជន៍របស់ភាគីដែលមិនធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ និងសិទ្ធិទទួលបានការជំនុំជម្រះក្តីក្នុងរយៈពេលសមស្រប។ ប៉ុន្តែ នៅក្នុងរឿងក្តីនេះ សេចក្តីសម្រេចស្តីអំពីការបកស្រាយអំពីការកំណត់ចំណុចចាប់ផ្តើមនៃកាលបរិច្ឆេទ ទោះមួយខែមុន ឬ មួយខែក្រោយក៏ដោយនៅក្នុងវិធាន៦៨នៃវិធានផ្ទៃក្នុង ក៏មិនបានកំម្រិត ឬ ធ្វើឲ្យបាត់បង់សិទ្ធិជាសារវន្តរបស់ជនជាប់ចោទឡើយ ជាពិសេសសិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាសមស្រប។

៣៣. យោងតាមសំអាងហេតុខាងលើ ការកំណត់លើចំណុចចាប់ផ្តើមនៃពេលវេលាកំណត់ក្នុងវិធាន៦៨(២)ដែលគិតពីថ្ងៃដាក់សារណាបណ្តឹងឧទ្ធរណ៍ មិនបានរំលោភលើវិធាន២១(១)នៃវិធានផ្ទៃក្នុង ឬ គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ឡើយ។

## ៤.៣ ទឡ្ហីករណ៍ទីមួយនៃបណ្តឹងសាទុក្ខ: ការគោរពច្បាប់នៃការបកស្រាយវិធាន ៦៨(៣)នៃវិធានផ្ទៃក្នុង

៣៤. អង្គជំនុំជម្រះតុលាការកំពូល កត់សំគាល់ឃើញថា រយៈពេលកំណត់ដែលលើកឡើងក្នុងទឡ្ហីករណ៍បណ្តឹងសាទុក្ខអំពី “រយៈពេលបួនខែ” ដូចមានចែងក្នុងវិធាន៦៨(២)និង(៣) ត្រូវផ្អែក

00702746



គិតចាប់ពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០។ ដោយយោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូល បានយល់ឃើញថារយៈពេលកំណត់បួនខែដែលមានចែងក្នុងវិធាន៦៨(២)នៃវិធានផ្ទៃក្នុង ដែលមានរយៈពេលបួនខែដូចគ្នា ទៅនឹងវិធាន៦៨(៣)នៃវិធានផ្ទៃក្នុងនៅពេលវិធាននេះដែលត្រូវអនុវត្តចំពោះសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតនោះ ត្រូវផ្តើមគិតចាប់ពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០១០ (នៅថ្ងៃដែលជនជាប់ចោទបាន ដាក់សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ) ហើយផុតរយៈពេលកំណត់ នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១។ ចាប់ពីថ្ងៃដែលអង្គបុរេជំនុំជម្រះ បានចេញសំអាងហេតុពេញលេញសំរាប់ផ្នែកសម្រេចសេចក្តីរបស់ខ្លួនលើសារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១១មកនោះ ពុំមានការរំលោភលើវិធាន៦៨(២)(៣) ឬ ៧៧(១៤)នៃវិធានផ្ទៃក្នុង ឡើយ។

៣៥. លើសពីនេះទៅទៀត ជនជាប់ចោទលើកឡើងនូវកំហុសឆ្គងផ្នែកអង្គច្បាប់នៅក្នុងសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា រយៈពេលកំណត់បួនខែនៃការឃុំខ្លួនបណ្តោះអាសន្ន ត្រូវចាប់ផ្តើមគិតពីថ្ងៃដែលអង្គជំនុំជម្រះសាលាដំបូង បានទទួលសំណុំរឿង០០២[54]ហើយថែមទាំងអះអាងថា មានរយៈពេលកំណត់បួនខែតែមួយគត់ដែលអាចអនុវត្តបាន[55]។ អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា វិធាន៦៨(២)-(៣)នៃវិធានផ្ទៃក្នុង អនុញ្ញាតឲ្យមានរយៈពេលបួនខែពីរផ្សេងគ្នា នៅពេលមានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ រយៈពេលកំណត់បួនខែទី១ ត្រូវចាប់ផ្តើមគិតពីថ្ងៃដាក់សារណារបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ហើយ រយៈពេលកំណត់បួនខែទីពីរត្រូវចាប់ផ្តើមគិតពីថ្ងៃចេញ "សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ"ស្របតាមអត្ថន័យនៃវិធាន៦៨(៣)នៃវិធានផ្ទៃក្នុង។ ហេតុដូច្នេះ ទឡ្ហីករណ៍បណ្តឹងសាទុក្ខនេះ ត្រូវបដិសេធចោលជាអសារបង់។

## ៤.៤ គ្មានវិការៈផ្នែកនីតិវិធី ឬ ការរំលោភបំពានលើសិទ្ធិរបស់ជនជាប់ចោទ

[54] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ៤៣។

[55] សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២-១៥។

៣៦. អង្គជំនុំជម្រះសាលាដំបូង បានយល់ឃើញថា "ការយឺតយ៉ាវរបស់អង្គបុរេជំនុំជម្រះក្នុងការផ្ដល់សំអាងហេតុចំពោះសាលដីការបស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍ គឺជាវិការៈផ្នែកនីតិវិធីដែលជាបឋមបានប៉ះពាល់ដល់សុវត្ថិភាពគតិយុត្ត និងសច្ចភាពផ្លូវច្បាប់នៃសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌"[56]។

៣៧. អង្គជំនុំជម្រះតុលាការកំពូល រំលឹកថា ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១ គឺជាថ្ងៃផុតកំណត់នៃរយៈពេលបួនខែដែលមានចែងក្នុងវិធាន៦៨(២)នៃវិធានផ្ទៃក្នុង ហើយអង្គបុរេជំនុំជម្រះ បានចេញសំអាងហេតុពេញលេញរបស់ខ្លួនសំរាប់រាល់ផ្នែកសម្រេចសេចក្ដីលើករណីជនជាប់ចោទ។ ផ្អែកតាមការបញ្ជាក់ខាងលើ ឃើញថា អង្គបុរេជំនុំជម្រះ បានគោរពតាមកិច្ចនីតិវិធីដូចមានចែងក្នុងវិធាន៦៨(២) និង៧៧(១៤)នៃវិធានផ្ទៃក្នុង ក្នុងការចេញនូវសេចក្ដីសម្រេចរបស់ខ្លួនក្នុងរយៈពេលកំណត់បួនខែ លើបណ្ដឹងឧទ្ធរណ៍របស់ជនជាប់ចោទប្រឆាំងនឹងដីកាដំណោះស្រាយ។ ដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចខាងលើរួចហើយនោះ អង្គបុរេជំនុំជម្រះ មិនបានប្រព្រឹត្តវិការៈផ្នែកនីតិវិធី ក្នុងការចេញសេចក្ដីសម្រេចហួសពេលកំណត់ នោះឡើយ។ ដោយមានហេតុទុកជាអសារបង់នៃធាតុសំខាន់ៗ ដូចនេះ មិនមានមូលដ្ឋានក្នុងការរក្សាទុកនូវសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា នីតិវិធីក្នុងការចេញសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះស្របតាមវិធាន៦៨(២)នៃវិធានផ្ទៃក្នុង មានការរំលោភលើសិទ្ធិរបស់ជនជាប់ចោទ។ នៅក្នុងការវិនិច្ឆ័យរបស់អង្គជំនុំជម្រះតុលាការកំពូល នៅខណៈដែលមិនគោរពតាមទំលាប់កន្លងមកមិនមានការបំពានណាមួយលើសិទ្ធិរបស់ជនជាប់ចោទ តាមវិធានផ្ទៃក្នុង និងមិនមានបញ្ហាការទូទាត់សំណងនោះទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល សម្រេចលុបចោលកថាខណ្ឌទីពីរ និងទីបីនៃផ្នែកសម្រេចសេចក្ដីរបស់អង្គជំនុំជម្រះសាលាដំបូង[57]។

---

[56] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទំព័រ២៩។

[57] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទំព័រ១៥៖

"**យល់ឃើញថា** ការពន្យាពេលក្នុងការចេញនូវសំអាងហេតុនៃការឃុំខ្លួននៅក្នុងផ្នែកសម្រេចសេចក្ដីរបស់ខ្លួនស្ដីពីដីកាដំណោះស្រាយ បានបណ្ដាលឲ្យមានការរំលោភបំពានលើសិទ្ធិរបស់ជនជាប់ចោទ។

**ប្រកាសថា** លក្ខណៈនៃសំណងដោយសារការរំលោភបំពាននេះ អាចត្រូវបានវាយតំលៃនៅពេលក្រោយ បន្ទាប់ពីបានស្ដាប់ភាគីស្ដីពីបញ្ហានេះ"។

## ៤.៥ ឧទ្ទិករណ៍ទីពីរនៃបណ្តឹងសាទុក្ខ: វិធាន៦៣(៣)នៃវិធានផ្ទៃក្នុង

៣៨. ក្នុងការរក្សាទុកជនជាប់ចោទក្នុងឃុំបណ្ដោះអាសន្នដោយអនុលោមតាមវិធាន៦៨(៣) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះ យល់ឃើញថា លក្ខខណ្ឌទាំងប្រាំនៃវិធាន៦៣(៣)(ខ) ត្រូវបានបំពេញ[58]ដូចដែលមាននៅក្នុងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត។ នៅក្នុងពេលសវនាការនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១ សហព្រះរាជអាជ្ញា លើកឡើងថា លក្ខខណ្ឌទាំងប្រាំនៅក្នុងវិធាន៦៣(៣)(ខ) នៅតែមានអត្ថិភាព[59]។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូង បង្គាប់ឱ្យរក្សាទុកជនជាប់ចោទក្នុងឃុំដោយផ្អែកតាមលក្ខខណ្ឌតែមួយប៉ុណ្ណោះ ក្នុងចំណោមលក្ខខណ្ឌទាំងប្រាំនេះដូចមានក្នុងវិធាន៦៣(៣)(ខ)(៣) ត្រង់ចំណុចដែលថា "...អាចប្រឈមមុខនឹងការផ្តន្ទាទោសធ្ងន់ធ្ងរ ប្រសិនបើតុលាការរកឃើញថាគាត់មានពិរុទ្ធ អាចមានចេតនាកាន់តែខ្លាំងក្នុងការរត់គេចខ្លួន[60]"។ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូង លើកឡើងថា អង្គជំនុំជម្រះ "បានពិចារណាផងដែរ ថាតើមូលដ្ឋាននានាដែលផ្អែកសម្រាប់រក្សាទុកជនជាប់ចោទក្នុងឃុំនៅក្នុងដីកាដំណោះស្រាយ និងសាលដីកា អ.ប.ជ លើបណ្តឹងឧទ្ធរណ៍នៅតែបំពេញដែរ ឬ យ៉ាងណា"[61] អង្គជំនុំជម្រះ បានបដិសេធ "ផ្នែកផ្សេងទៀតនៃសារណារបស់សហព្រះរាជអាជ្ញា ដែលបានលើកឡើងដើម្បីគាំទ្រចំពោះ

---

[58] សេចក្តីសម្រេចមានសំអាងហេតុពេញលេញ កថាខណ្ឌ២៩ (អង្គបុរេជំនុំជម្រះ "តម្កល់"សំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាដំណោះស្រាយ កថាខណ្ឌ១៦២២-១៦២៤)។

[59] ប្រតិចារឹក ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១, ឯកសារលេខ E1/1.1,ERN 00642325-00642411(EN), ទំព័រ៥៥-ជួរទី៩, ទំព័រ៥៩-ជួរទី៧(លោក Andrew CAYLEY លើកឡើងលក្ខខណ្ឌប្រាំទាក់ទងនឹង នួន ជា), ទំព័រ៦៥-ជួរ២២ , ទំព័រ៦៧-ជួរ១១ (លោកស្រី ជា លាង លើកឡើងវិធាន៦៣(៣)(ខ)ទាក់ទងទៅនឹង ខៀវ សំផន និង អៀង ធីរិទ្ធ ហើយលើកឡើងថា "ខ្ញុំសូមបន្ថែមនូវអ្វីដែលសហការីរបស់ខ្ញុំ បានលើកឡើងទាក់ទងទៅនឹង នួន ជា"), ទំព័រ៧៩,ជួរទី២១-ទំព័រ៨៣,ជួរទី២(លោក ស សូវាន លើកឡើងថា ខៀវ សំផន "នឹងមិនរត់គេចខ្លួនទេ") ក្នុងការឆ្លើយតបទៅនឹងសារណាផ្ទាល់មាត់របស់លោក Andrew CAYLEY ទាក់ទងទៅនឹង នួន ជា លើវិធាន ៦៣(៣)(ខ)(៣)។

[60] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ៤០។

[61] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ៣៨។

00702749



ការរក្សាទុកជនជាប់ចោទក្នុងឃុំ”[62]។ ដូចនេះ ពុំមានសំអាងហេតុណាមួយ ឬ អ្វីផ្សេងទៀត ត្រូវបានផ្តល់ឲ្យដើម្បីគាំទ្រការបដិសេធនេះទេ[63]។

៣៩. វិធាន៦៣(៣)នៃវិធានផ្ទៃក្នុងចែងថា សហចៅក្រមស៊ើបអង្កេតអាចបង្គាប់ឲ្យធ្វើការឃុំខ្លួនបាន នៅពេលដែលលក្ខខណ្ឌពីរ ត្រូវបានបំពេញ។ លក្ខខណ្ឌទីមួយនៃវិធាន៦៣(៣)(ក) គឺ ជាលក្ខខណ្ឌនៃមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយដែលត្រូវបានចោទប្រកាន់។ នេះគឺជាវិសាលភាពទូទៅមួយ ដែលត្រូវតែបង្ហាញដោយវិជ្ជមាន ដើម្បីធ្វើការពិចារណាលើលក្ខខណ្ឌជាក់លាក់ណាមួយសំរាប់ការឃុំខ្លួនតាមចំនុច(ខ)។ លក្ខខណ្ឌទីពីរ គឺថា យ៉ាងហោចណាស់ត្រូវមានមូលដ្ឋានមួយក្នុងចំណោមមូលដ្ឋានទាំងប្រាំ ដែលបានរៀបរាប់នៅក្នុងវិធាន៦៣(៣)(ខ)នៃវិធានផ្ទៃក្នុង។

៤០. ក្នុងការវាយតម្លៃថាតើ លក្ខខណ្ឌនៃវិធាន ៦៣(៣)(ខ)(៣)នៃវិធានផ្ទៃក្នុងបានបំពេញ ឬ យ៉ាងណា អង្គជំនុំជម្រះតុលាការកំពូល យល់ស្របទៅនឹងអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY ថា:

> គឺជាការសមហេតុផលមួយហើយដែល អង្គជំនុំជម្រះសាលាដំបូង ត្រូវធ្វើការពិចារណាអំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលចោទប្រកាន់ ដើម្បីកំណត់ថាតើ បញ្ហាប្រឈមចំពោះលទ្ធភាពនៃការដាក់ទោសធ្ងន់ធ្ងរ អាចបង្កើតចេតនាក្នុងការរត់គេចខ្លួនរបស់ជនជាប់

---

[62] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ៤០។

[63] ទាក់ទងនឹង នួន ជា , ជាជនជាប់ចោទទីមួយក្នុងចំណោមជនជាប់ចោទបីនាក់ដែលអង្គជំនុំជម្រះសាលាដំបូង ធ្វើការពិចារណា នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះអះអាងថា “ធ្វើការបដិសេធផ្នែកផ្សេងទៀតនៃសារណារបស់សហព្រះរាជអាជ្ញាដែលបានលើកឡើងដើម្បីគាំទ្រដល់ការឃុំខ្លួនបន្តដោយ ផ្អែកលើមូលដ្ឋានខ្វះនូវការបង្ហាញភស្តុតាង”។ (សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងកថាខណ្ឌ៣៩ មានការបញ្ជាក់បន្ថែម)។ សំរាប់ជនជាប់ចោទ ពីរនាក់ទៀត ខៀវ សំផន និង អៀង ធីរិទ្ធ អង្គជំនុំជម្រះសាលាដំបូងលើកឡើងថា “បដិសេធចោលនូវផ្នែក ផ្សេងទៀតនៃសារណារបស់សហព្រះរា[illegible] រក្សាទុកក្នុងឃុំ”។ (សេចក្តីសម្រេចរបស់អង្គ ជំនុំជម្រះសាលាដំបូង កថាខណ្ឌ៤០-៤១)

ចោទ។ មានភស្តុតាងបង្ហាញថា នៅពេលដែលជនជាប់ចោទប្រឈមមុខនឹងការដាក់ទោស កាន់តែធ្ងន់នោះ ចេតនាក្នុងការរត់គេចខ្លួនកាន់តែមានខ្លាំងឡើង ដែរ[64]។

ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូល រំលឹកថា បទដ្ឋានអន្តរជាតិចែងច្បាស់ថា "ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលចោទប្រកាន់ គឺគ្រាន់តែជាកត្តាមួយក្នុងចំណោមកត្តានានាដែលអង្គជំនុំជម្រះសាលាដំបូង ធ្វើការពិចារណាក្នុងការវាយតម្លៃថាតើ ជនជាប់ចោទនឹងបង្ហាញខ្លួនចំពោះមុខអង្គជំនុំជម្រះ ដែរ ឬ ទេ ប្រសិនបើត្រូវបានដោះលែង នោះ"[65]។ ការរំពឹងទុកជាមុនអំពីការដាក់ទោសធ្ងន់ធ្ងរ មិនអាចធ្វើបានឡើយក្នុងចំពោះជនជាប់ចោទ ក្នុងន័យមិនច្បាស់លាស់ ដែលជាកត្តាតែមួយគត់ក្នុងការកំណត់ពីលទ្ធផលនៃពាក្យស្នើសុំដោះលែង ដោយហេតុថា ជនជាប់ចោទទាំងអស់នៅចំពោះមុខ អ.វ.ត.ក ប្រសិនបើមានពិរុទ្ធភាពនោះទំនងជាប្រឈមមុខនឹងការដាក់ទោសធ្ងន់ធ្ងរ[66]។

៤១. ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា ទោះបីជាអង្គជំនុំជម្រះសាលាដំបូង បានសំអាងលើមូលដ្ឋានគតិយុត្តត្រឹមត្រូវក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូង មានសំអាងហេតុដែលមិនរឹងមាំ ដោយចាត់ទុកការដាក់ទោសធ្ងន់ធ្ងរគឺជាកត្តាដ៏មានសក្តានុពលមួយ ដូច្នេះ ជាការពុំបានថ្លឹងថ្លែងសមស្របអំពីយុត្តិកម្មក្នុងការរក្សាទុកជនជាប់ចោទក្នុងឃុំជាបណ្តោះអាសន្ននោះ[67]។

---

[64] រដ្ឋអាជ្ញាទល់នឹង Ivan Cermak and Mladen Markac, សេចក្តីសម្រេចលើបណ្តឹងរបៀងប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបដិសេធការដោះលែងបណ្តោះអាសន្ន សំណុំរឿងលេខ IT-03-73-AR65.1, អង្គជំនុំជម្រះតុលាការកំពូល,ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០០៤កថាខណ្ឌ២៥។

[65] រដ្ឋអាជ្ញា *ទល់នឹង* Jovica Stanisic, សេចក្តីសម្រេចស្តីពីការដោះលែងជាបណ្តោះអាសន្នសំណុំរឿងលេខ IT-03-69-PT អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ២២។ សូមមើល រដ្ឋអាជ្ញា *ទល់នឹង* Vujdin Popovic, ទំព័រ៥។ រដ្ឋអាជ្ញាទល់នឹង Zdravko Tolimir, អង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌ២៥-២៦ និង Ilijkov *ទល់នឹង* Bulgaria, តុលាការអឺរ៉ុបនៃសិទ្ធិមនុស្ស, សាលក្រមចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០១ កថាខណ្ឌ៨១។

[66] រដ្ឋអាជ្ញាទល់នឹង Jadranko Prlic, ដីការបង្គាប់ឱ្យដោះលែងបណ្តោះអាសន្នរបស់ Jadranko Prlic, សំណុំរឿងលេខ IT-04-74-PT, អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ២៩; រដ្ឋអាជ្ញាទល់នឹង Ivan Cermak និង Mladen Markac, អង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌ២៦។

[67] សូមមើល រដ្ឋអាជ្ញាតទល់នឹង Ivan Cermak និង Mladen Markac កថាខណ្ឌ២៧។

00702751



៤២. អង្គជំនុំជម្រះតុលាការកំពូល នឹងធ្វើការពិចារណាលើផលវិបាកនៃសំអាងហេតុមិនគ្រប់គ្រាន់របស់អង្គជំនុំជម្រះសាលាដំបូង។ ជនជាប់ចោទ លើកឡើងថា សំអាងហេតុមិនគ្រប់គ្រាន់ បានធ្វើឱ្យ "បាត់សុពលភាពនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង៖ ក្នុងករណីដែលការផ្តល់មូលហេតុលើការឃុំខ្លួន ពុំមានបញ្ជាក់ដោយលក្ខណៈវិនិច្ឆ័យផ្សេងក្រៅពីពាក្យពេចន៍ដែលមានចែងតែនៅក្នុងវិធាន៦៣(៣)(ខ)(៣)នៃវិធានផ្ទៃក្នុង ត្រូវតែដោះលែងដើមបណ្តឹងសាទុក្ខឱ្យមានសេរីភាព"[68]។ ក្នុងសារណាតបរបស់ខ្លួន សហព្រះរាជអាជ្ញាលើកឡើងថា ការបន្តរក្សាទុកជនជាប់ចោទក្នុងឃុំបណ្តោះអាសន្ន គឺមានមូលដ្ឋានស្របតាមវិធាន៨២(១)នៃវិធានផ្ទៃក្នុង ប៉ុន្តែ ឋិតនៅក្នុងឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះតុលាការកំពូល "ក្នុងការពិនិត្យឡើងវិញនូវអង្គហេតុនានា ហើយអាចសម្រេចតំកល់ ឬ កែប្រែសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយរួមទាំងការផ្តល់នូវសំអាងហេតុផលរបស់ខ្លួនផង"[69]។ សហព្រះរាជអាជ្ញា ដាក់ជូននូវសំអាងហេតុដែលពួកគេចាត់ទុកថាមានលក្ខណៈគ្រប់គ្រាន់សំរាប់អង្គជំនុំជម្រះតុលាការកំពូល សម្រេចបន្តរក្សាទុកជនជាប់ចោទក្នុងឃុំជាបណ្តោះអាសន្ន ដោយយោងតាមវិធាន៦៣(៣)(ខ)(៤)(៥)[70]នៃវិធានផ្ទៃក្នុង។ ដោយយោងតាមសំអាងហេតុខាងក្រោមនេះ អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា សំអាងហេតុរបស់សហព្រះរាជអាជ្ញាមិនមានលក្ខណៈសមស្របទេ ទាំងចំណុចស្តីពីការដោះលែងជនជាប់ចោទ ឬ ទាំងការពិចារណាថាតើ លក្ខខណ្ឌបន្ថែមណាមួយដែលមានចែងក្នុងវិធាន៦៣(៣)(ខ)នៃវិធានផ្ទៃក្នុង ត្រូវការចាំបាច់ នោះ។

៤៣. វាក្យខ័ណ្ឌទីពីរនៃវិធាន៨២(១)នៃវិធានផ្ទៃក្នុងចែងថា " ក្នុងករណីដែលជនជាប់ចោទ ត្រូវបានឃុំខ្លួននៅពេលចូលខ្លួនលើកដំបូង នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ជនជាប់ចោទ ត្រូវស្ថិតនៅក្នុងឃុំដដែលរហូតដល់ពេលសាលក្រមនៃអង្គជំនុំជម្រះសាលាដំបូង ត្រូវបានសម្រេចសេចក្តីលើកលែងតែករណីដែលមានចែងក្នុងអនុវិធាន២"។ វិធាននេះ ត្រូវបានកែសម្រួលដោយអ.វ.ត.ក

[68] សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ២៣។ (ការបញ្ជាក់ក្នុងឯកសារដើម)

[69] សារណាតប កថាខណ្ឌ១៩។

[70] សារណាតប កថាខណ្ឌ១៩-២៨។

ពីមាត្រា៣០៥-៣០៧នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ មានបញ្ហាបកស្រាយមួយចំនួនដែលកើតចេញពីមូលដ្ឋាននៃបទប្បញ្ញត្តិនេះ។

៤៤. បញ្ហាទីមួយ ទាក់ទងនឹង“ការបង្ហាញខ្លួនលើកដំបូង”។ អង្គជំនុំជម្រះតុលាការកំពូល ពិចារណាឃើញថា ការបង្ហាញខ្លួនលើកដំបូងដែលយោងទៅលើវិធាន ៨២(១) មានន័យខុសគ្នាពីសវនាការបឋមដែលជាការចាប់ផ្តើមនៃការជំនុំជម្រះ ដោយអនុលោមតាមវិធាន ៨០ស្ទួន(១) ហើយរួមបញ្ចូលទាំងការបង្ហាញខ្លួនណាមួយរបស់ជនជាប់ចោទ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ទោះបីជាតាមសំណើសុំរបស់ខ្លួន ឬ តាមការបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង និងពាក់ព័ន្ធទៅនឹងបញ្ហាណាមួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូង នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងទទួលបានសំណុំរឿង ក៏ដោយ។ ក្នុងន័យនេះ ការបង្ហាញខ្លួនលើកដំបូង ចាត់ទុកជាដំណើរការនៃសវនាការព្រហ្មទណ្ឌដែលតុលាការពិនិត្យអំពីនីត្យានុកូលភាពនៃការផ្តន្ទាទោសក្នុងរឿងក្តី។ អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា សវនាការដែលអង្គជំនុំជម្រះសាលាដំបូងដែលបានធ្វើឡើងនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១ គឺជា “ការបង្ហាញខ្លួនលើកដំបូង”ស្របទៅតាមអត្ថន័យនៃវិធាន៨២(១)នៃវិធានផ្ទៃក្នុង ពីព្រោះ ជាលើកដំបូងដែលជនជាប់ចោទបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង បន្ទាប់ពី អង្គជំនុំជម្រះនេះ ទទួលបានសំណុំរឿង០០២។

៤៥. បញ្ហាទីពីរ ទាក់ទងនឹង“ការរក្សាទុកជនជាប់ចោទក្នុងឃុំបណ្តោះអាសន្ន”។ អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា ឃ្លាដែលថា“ក្នុងករណីដែលជនជាប់ចោទស្ថិតក្នុងឃុំ”អនុលោមតាមវិធាន៨២(១)នៃវិធានផ្ទៃក្នុង ចាំបាច់ត្រូវតែកំណត់ន័យថា ការឃុំខ្លួន ត្រូវតែមានមូលដ្ឋានច្បាប់នៅក្នុងសេចក្តីសម្រេចរបស់តុលាការ។ អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញដូចខាងលើថា អង្គបុរេជំនុំជម្រះ បានអនុវត្តស្របតាមការកំណត់រយៈពេលបួនខែ ដោយអនុលោមតាមវិធាន៦៨(២)(៣)។ ហេតុដូច្នេះ មិនមានការពិចារណាតទៅទៀតឡើយ នៅពេលដែលថា ជនជាប់ចោទត្រូវបានឃុំខ្លួនជាបណ្តោះអាសន្នដោយស្របច្បាប់ នៅពេលបង្ហាញខ្លួនលើកដំបូងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១។

៤៦. បញ្ហាដែលលំបាកជាងនេះទៅទៀតនោះ គឺទាក់ទងទៅនឹងអត្ថន័យគតិយុត្ត នៃវិធាន៨២(១)នៃវិធានផ្ទៃក្នុង មានន័យដូចទៅនឹង មាត្រា៣០៥(៥)នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ អង្គជំនុំជម្រះតុលាការកំពូល កត់សំគាល់ឃើញថា ប្រព័ន្ធច្បាប់កម្ពុជា បានការពារយ៉ាងខ្លាំងចំពោះសិទ្ធិទទួលបានសេរីភាព[71]។ មាត្រា៩នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងអំពីការសន្មត់ទុកជាមុននូវសិទ្ធិទទួលបានសេរីភាព ដូចជា លក្ខខណ្ឌនៃនីត្យានុកូលភាព និងការហាមឃាត់នូវការចាប់ឃុំខ្លួនតាមអំពើចិត្ត។ ការដកហូតសេរីភាព មិនត្រូវបានអនុញ្ញាតឡើយលើកលែងតែមានហេតុផលនិងស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់[72]។ ជនណាដែលត្រូវបានចាប់ខ្លួនពីបទព្រហ្មទណ្ឌ ត្រូវតែទទួលបានការជំនុំជម្រះក្នុងពេលសមស្រប ឬ ត្រូវដោះលែង[73]ហើយការឃុំខ្លួនមនុស្ស[74]ដើម្បីរង់ចាំការជំនុំជម្រះ គឺមិនមែនជាវិធានទូទៅទេ។ បញ្ហានេះដូចគ្នា នៅក្នុងប្រព័ន្ធអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ការសន្មត់ទុកជាមុន ត្រូវបានជាប្រយោជន៍ដល់ការដោះលែងហើយ យុត្តិសាស្ត្រ ក៏បានបញ្ជាក់ដូច្នេះដែរ[75]។ ក្របខណ្ឌគតិយុត្តដែលអនុវត្តនៅអ.វ.ត.ក មិនបានដកចេញនូវការសន្មត់ទុកជាមុននៃសិទ្ធិមានសេរីភាព សំរាប់ជនជាប់ចោទនៅក្នុងមាត្រា៩នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឡើយ។ ហេតុដូច្នេះ វិធាន៨២(១)នៃវិធានផ្ទៃក្នុង និងមាត្រា៣០៥-៣០៧នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវតែមានអត្ថន័យពាក់ព័ន្ធនឹងការសន្មត់ទុកជាមុននៃសិទ្ធិមានសេរីភាពនេះ។ ផលវិបាកជាច្រើនកើតចេញពីនេះ។

---

71 សូមមើលរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣១,៣២ និង៣៨ និង៤២។ លើសពីនេះ កម្ពុជាគឺជាភាគីនៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ ចាប់តាំងពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២។ សូមមើល យោងតាមការអនុវត្តនៃសិទ្ធិសញ្ញាស្តីពីសិទ្ធិមនុស្សអន្តរជាតិនៅក្នុងកម្ពុជា សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា លេខ១៣១/០០៣/២០០៧ សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ , ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧។

72 កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយមាត្រា៩(១)។

73 កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយមាត្រា៩(៣) ។

74 ដូចខាងលើ

75 Kudła *តទល់* Poland [GC],តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស សាលដីកាតុលាការកំពូល ឯកសារលេខ 30210/96 ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០០, កថាខណ្ឌ១១០-១១១។



SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME E.C.C.C * C.E.T.C

៤៧. ការសន្មត់ទុកជាមុននៃសិទ្ធិមានសេរីភាពនេះ មានន័យផងដែរថា ការឃុំខ្លួនជនជាប់ចោទ គ្រប់ករណីទាំងអស់ ត្រូវតែមានមូលដ្ឋាននៅក្នុងសេចក្តីសម្រេចរបស់តុលាការ ដែលត្រូវចេញឱ្យស្រប តាមនីតិវិធី និងលក្ខខណ្ឌដែលមានចែងក្នុងច្បាប់។ ទាំងវិធាន៨២(១) និងមាត្រា៣០៥(៥)នៃ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា កំណត់ថា "ក្នុងករណីដែលជនជាប់ចោទត្រូវបានឃុំខ្លួននៅពេលចូល ខ្លួនលើកដំបូង ត្រូវស្ថិតនៅក្នុងឃុំរហូតដល់ពេលសាលក្រមត្រូវបានសម្រេច"។ លទ្ធផលនៃបទ ប្បញ្ញត្តិទាំងនេះ គឺ ថាអានុភាពនៃការបន្តរក្សាទុកជនជាប់ចោទក្នុងឃុំបណ្តោះអាសន្ន កើតចេញ ពីសេចក្តីបង្គាប់ឱ្យឃុំខ្លួនរបស់អាជ្ញាធរតុលាការដែលមានពីមុនមក។ ហេតុដូច្នេះ វិធាន៨២(១) ត្រូវមានន័យស្របគ្នានឹងគោលការណ៍នៃការសន្មត់ទុកជាមុនដែលថា លក្ខខណ្ឌសំរាប់ការឃុំខ្លួន ដែលបង្គាប់ដោយអាជ្ញាធរតុលាការពីមុនមក មានជាអាទិ៍ ដោយសហចៅក្រមស៊ើបអង្កេត នៅក្នុងនីតិវិធីតទល់ ហើយដែលមានការពិនិត្យឡើងវិញ ដោយអង្គបុរេជំនុំជម្រះ ត្រូវបន្តអនុវត្ត នៅពេលដែលសំណុំរឿងបញ្ជូនទៅជំនុំជម្រះ។ លើសពីនេះទៅទៀត វិធាន៨២ មិនមានន័យជាការ អនុញ្ញាតឱ្យឃុំខ្លួនជនជាប់ចោទដោយមិនបង្ហាញលក្ខខណ្ឌផ្លូវច្បាប់នោះឡើយ។ ការយល់បែបនេះ ត្រូវបានបញ្ជាក់ច្បាស់លាស់ ដោយពាក្យពេចន៍នៃមាត្រា៣០៦នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែល ចែងថា"នៅគ្រប់ពេលវេលា តុលាការអាចបង្គាប់ឱ្យដោះលែងជនជាប់ចោទដែលជាប់ឃុំឱ្យមាន សេរីភាពវិញបាន ឬឱ្យបន្តការឃុំខ្លួនជនជាប់ចោទដោយយោង *តាមមាត្រា២០៥នៃក្រមនេះ [(មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន)]"*។

៤៨. លើសពីនេះទៀត គោលការណ៍នៃការសន្មត់ទុកជាមុនអំពីលក្ខខណ្ឌសំរាប់ការឃុំខ្លួនដែលមានវិធាន ៨២(១)នៃវិធានផ្ទៃក្នុង គឺជាគោលការណ៍នៃការសន្មត់ទុកជាមុនតាមអង្គហេតុ ដែលមិនចងកាតព្វ កិច្ចចំពោះតុលាការជំនុំជម្រះឡើយ។ វាក្យខ័ណ្ឌទីមួយនៃវិធាន៨២(២)នៃវិធានផ្ទៃក្នុងចែងថា "អង្គជំនុំជម្រះសាលាដំបូង គ្រប់ពេលនៃកិច្ចដំណើរការនីតិវិធី អាចបង្គាប់ឱ្យដោះលែងជនជាប់ ចោទ ឬ ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ក្នុងករណីចាំបាច់ ឬ បង្គាប់ឱ្យឃុំ ខ្លួនជនជាប់ចោទបាន ស្របតាមវិធានផ្ទៃក្នុងនេះ"។ បញ្ហានេះ អាចជំទាស់បាន ដូចដែលបាន បង្ហាញនៅក្នុងវាក្យខ័ណ្ឌទីមួយនៃវិធាន៨២(៣)នៃវិធានផ្ទៃក្នុង ដែលចែងថា "ជនជាប់ចោទ ឬ មេធាវីរបស់ខ្លួន អាចស្នើសុំដោយផ្ទាល់មាត់ក្នុងពេលសវនាការ ឬ ដោយលិខិតជាលាយលក្ខណ៍ អក្សរ ដាក់ជូនក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូង"។ ស្របតាមបទប្បញ្ញត្តិនេះ ចាប់តាំងពី

បង្ហាញខ្លួនលើកដំបូង រហូតដល់ពេលការចេញសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង គឺជាបន្ទុករបស់ជនជាប់ចោទ ក្នុងការតវ៉ាប្រឆាំងទៅនឹងមូលដ្ឋាននៃការឃុំខ្លួនតាមការស្នើសុំទៅអង្គជំនុំជម្រះសាលាដំបូង។

៤៩. នៅពេលបង្ហាញខ្លួនលើកដំបូង តាមការស្នើសុំរបស់ជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូង តម្រូវឲ្យពិចារណាថាតើ លក្ខខណ្ឌសំរាប់រក្សាទុកជនជាប់ចោទក្នុងឃុំបណ្តោះអាសន្នស្របតាមវិធាន៦៣(៣)នៃវិធានផ្ទៃក្នុង នៅតែអាចអនុវត្តបាន ឬទេ។ អង្គជំនុំជម្រះសាលាដំបូង អាចពិនិត្យឡើងវិញផងដែរអំពីនីត្យានុកូលភាពនៃការឃុំខ្លួននេះតាមការយល់ឃើញរបស់ខ្លួន។ ដោយសារក្នុងករណីនេះ ជនជាប់ចោទ នៅក្នុងសំណើសុំដោះលែងរបស់ខ្លួន មិនបានតវ៉ាទៅនឹងលក្ខខណ្ឌនៃការឃុំខ្លួនដែលមានចែងក្នុងវិធាន៦៣(៣)(ខ)នោះ អង្គជំនុំជម្រះសាលាដំបូង មិនតម្រូវឲ្យពិចារណាថាតើ លក្ខខណ្ឌទាំងនេះ ត្រូវបានបំពេញ ដែរឬទេ ហើយអង្គជំនុំជម្រះ អាចសំអាងលើការសន្និដ្ឋានទុកជាមុនដែលមានចែង នៅក្នុងវិធាន៨២(១)បាន។ អង្គជំនុំជម្រះសាលាដំបូង គ្រាន់តែតម្រូវឲ្យសម្រេចលើសំណើរបស់ជនជាប់ចោទ ប៉ុណ្ណោះ។ ប៉ុន្តែ ក្នុងករណីនេះ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចលើសពីវិសាលភាពនៃសំណើសុំដោះលែងរបស់ជនជាប់ចោទ ដោយសម្រេចពិចារណាជាថ្មី ថាតើ លក្ខខណ្ឌដែលមានចែង ក្នុងវិធាន ៦៣(៣)នៃវិធានផ្ទៃក្នុង ត្រូវបានបំពេញដែរឬទេ។ ដូចបានពិចារណាខាងលើ ខណៈដែលអង្គជំនុំជម្រះសាលាដំបូង មានអំណាចពេញលេញក្នុងការពិនិត្យឡើងវិញយ៉ាងដូច្នេះ នោះជាលទ្ធផលបង្កើតឲ្យមានការព្រួយបារម្ភ។

៥០. អង្គជំនុំជម្រះសាលាដំបូង បានដកចេញទាំងស្រុងនូវលក្ខខណ្ឌពិសេសៗជាច្រើនដែលបានលើកឡើងពីមុនសំរាប់ការឃុំខ្លួន ដែលនាំឲ្យមានមោឃភាពដល់ការសន្និដ្ឋានទុកជាមុននៃការបន្តការរក្សាទុកក្នុងឃុំបណ្តោះអាសន្នក្នុងដំណាក់កាលជំនុំជម្រះ។ ការរក្សាទុកលក្ខខណ្ឌតែមួយគត់ដែលមានសុពលភាពស្របតាមវិធាន៦៣(៣)(ខ)(៣)នៃវិធានផ្ទៃក្នុង ដោយអង្គជំនុំជម្រះសាលាដំបូង ដូចដែលបានពិចារណាខាងលើ មិនមានលក្ខណៈគ្រប់គ្រាន់ នៅឡើយ។

៥១. ទាក់ទងនឹងវិធាន៨២(២)នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា [illegible] អង្គជំនុំជម្រះសាលាដំបូងស្តាប់គូភាគី អង្គជំនុំជម្រះ ត្រូវអនុញ្ញាតឲ្យភាគីមាន[illegible]



SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME
E.C.C.C * C.E.T.C

បាយគ្រប់គ្រាន់សំរាប់ត្រៀមរៀបចំនៅពេលសវនាការ។ ក្នុងករណីនេះ អង្គជំនុំជម្រះសាលាដំបូងជាដំបូង បានប្រាប់ដល់គូភាគី ក្នុងពេលសវនាការថា គួរធ្វើការពិចារណាអំពីវិធាន៦៣(៣)នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះសាលាដំបូង មិនបានជូនដំណឹងដល់ភាគីនៅមុនពេលសវនាការដើម្បីត្រៀមរៀបចំសារណាស្តីពីវិធាន៦៣(៣)នៃវិធានផ្ទៃក្នុង ឡើយ។ ដោយមិនបានផ្តល់នូវការជូនដំណឹងគ្រប់គ្រាន់អំពីបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងមិនអាចទទួលបាននូវសារណាពេញលេញ និងមិនបានស្តាប់ឲ្យបានត្រឹមត្រូវពីភាគីទាំងអស់អំពីវិធាន៦៣(៣)នេះឡើយ។ នេះជាការលើកបង្ហាញរបស់សហព្រះរាជអាជ្ញាក្នុងសារណាតបរបស់ខ្លួន នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលឲ្យទទួលយកអំពីហេតុការណ៍នានាដែលពង្រឹងដល់វិធាន៦៣(៣)(ខ)(៤)និង(៥)ដែលមាននៅពេលសវនាការ ប៉ុន្តែ សហព្រះរាជអាជ្ញា មិនបានដាក់ជូនអង្គជនុំជម្រះសាលាដំបូងនៅពេលសវនាការ ឡើយ។ អង្គជំនុំជម្រះតុលាការកំពូល ពិចារណាឃើញថា ការដែលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង មិនតម្រូវឲ្យជនជាប់ចោទ បង្ហាញនូវការប្រែប្រួលស្ថានភាពនៅក្នុងសំណើសុំដោះលែងជាថ្មី គឺសំណាងដែលសមស្របដោយសារការខកខានមិនបានជូនដំណឹងជាមុនអំពីការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូងលើវិធាន៦៣(៣) មិនមានផលប៉ះពាល់ដល់ការយល់ឃើញដែលថា អង្គជំនុំជម្រះសាលាដំបូង មិនបានធ្វើការពិនិត្យឡើងវិញឲ្យបានម៉ត់ចត់។

៥២. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា មិនមានលក្ខណៈសមស្របទេក្នុងការពិចារណា ថាតើលក្ខខណ្ឌដទៃទៀតនៅក្នុងវិធាន៦៣(៣)(ខ)នៃវិធានផ្ទៃក្នុង ត្រូវបានបំពេញ ដែរឬទេនោះ។ ជាតុលាការចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូល ត្រូវពិនិត្យឡើងវិញអំពីសេចក្តីសម្រេចដែលតវ៉ាតែទៅលើ ទទ្បីករណ៍នៃបណ្តឹងសាទុក្ខ និងស្របតាមគោលបំណងនៃបណ្តឹងសាទុក្ខប៉ុណ្ណោះ។ ដោយសារសហព្រះរាជអាជ្ញា សម្រេចមិនប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង យុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿងនេះ ពាក់ព័ន្ធតែទៅលើ ទទ្បីករណ៍តែមួយនៃការឃុំខ្លួន នោះគឺថា ការធានាឲ្យមានវត្តមានរបស់ជនជាប់ចោទក្នុងដំណើរការនីតិវិធី។ លើសពីនេះទៅទៀត លទ្ធផលនៃបណ្តឹងសាទុក្ខ ដែលបានដាក់ដោយជនជាប់ចោទតែឯង មិនត្រូវធ្វើឲ្យប៉ះពាល់ដល់ប្រយោជន៍ជនជាប់ចោទ (ករណីដែល ប្តឹងសាទុក្ខតែឯង តុលាការជាន់ខ្ពស់មិនអាចបន្ថែមទោសបានឡើយ) ជា

មានចែងក្នុងវិធាន១១០(៣)នៃវិធានផ្ទៃក្នុង មាត្រា៣៩៩(១)នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហើយដែលឆ្លុះបញ្ចាំងគោលការណ៍យុត្តិធម៌ជាមូលដ្ឋាន ហេតុដូច្នេះ បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទតែឯងដែលប្រឆាំងតែទៅនឹងលក្ខខណ្ឌនៃការឃុំខ្លួនតែមួយគត់ ដែលលើកឡើងដោយសេចក្តីសម្រេចរបស់តុលាការជាន់ដំបូង មិនអាចនាំទៅដល់ការសំអាងហេតុនូវលក្ខខណ្ឌបន្ថែមសំរាប់ការរក្សាទុកជនជាប់ចោទក្នុងឃុំបណ្តោះអាសន្នដោយតុលាការជាន់ខ្ពស់បានឡើយ។ ហេតុដូច្នេះ ខណៈដែលសហព្រះរាជអាជ្ញា យល់ឃើញថាជាការត្រឹមត្រូវ គឺ តុលាការជាន់ខ្ពស់ អាចដាក់សំអាងហេតុជំនួសសំអាងហេតុដែលខុសឆ្គងនៃសេចក្តីសម្រេចរបស់តុលាការជាន់ដំបូងបាន ប៉ុន្តែ ត្រូវចងចាំថាបញ្ហានេះ ត្រូវតែជាកម្មវត្ថុនៃបណ្តឹងសាទុក្ខ និងមានសំអាងហេតុដែលអាចឱ្យធ្វើការកែតម្រូវបាន។

៥៣. ទាក់ទងនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលបានយោងនៅក្នុងសារណាតបរបស់សហព្រះរាជអាជ្ញាដើម្បីគាំទ្រដល់ការដាក់ជំនួសសំអាងហេតុរបស់តុលាការជាន់ដំបូង[76] អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ មានលក្ខណៈខុសពីនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលដោយសារមូលហេតុចំនួនពីរយ៉ាង។ ទីមួយ សេចក្តីសម្រេច នេះ ពាក់ព័ន្ធទៅនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចទាំងមូលរបស់តុលាការជាន់ដំបូង។ ទីពីរ វិសាលភាពនៃការពិនិត្យឡើងវិញរបស់អង្គបុរេជំនុំជម្រះលើដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត យ៉ាងហោចណាស់ នៅពេលដែលបកស្រាយ មិនបានកម្រិតដូចមូលដ្ឋានដែលមានចែងក្នុងនៃវិធាន១០៤នៃវិធានផ្ទៃក្នុង នោះទេ[77]។ គួរកត់សំគាល់ថា សេចក្តីសម្រេចថ្មីៗ របស់អង្គបុរេជំនុំជម្រះ ដែលសហព្រះរាជអាជ្ញាបានលើកឡើងជូនអង្គជំនុំជម្រះតុលាការកំពូល ក្នុងការអនុវត្តតាមបទដ្ឋានរបស់តុលាការ ICTY ស្តីពីវិសាលភាពនៃការពិនិត្យ

---

[76] សារណាតប កថាខណ្ឌ៥។ ជើងទំព័រ១០។

[77] បទដ្ឋាននៃការពិនិត្យឡើងវិញរបស់អង្គបុរេជំនុំជម្រះ បានកើតឡើងនៅពេលដែលសេចក្តីសម្រេច ត្រូវបានដកស្រង់ដោយសារណាតប ដូចបង្ហាញដោយសេចក្តីសម្រេចលេខ D164/3/6 ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ , D164/4/13 ថ្ងៃទី... ខែ... ឆ្នាំ២០០៩ D97/14/15 ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០។

00702758



ឡើងវិញ[78] ដែលមានបញ្ជាក់ក្នុងកថាខណ្ឌផ្សេងទៀត ថា"អង្គបុរេជំនុំជម្រះ កត់សំគាល់ឃើញថា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ មានវិសាលភាពនៃការពិនិត្យឡើងវិញដោយមានកម្រិតបំផុតនៅពេលដោះស្រាយលើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចឆន្ទានុសិទ្ធិរបស់តុលាការជាន់ដំបូង"។ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ បានដកស្រង់សេចក្តីសម្រេចរបស់តុលាការ ICTY ស្តីពីការធ្វើអន្តរាគមន៍ដោយមានកម្រិតទៅលើការយល់ឃើញដោយឆន្ទានុសិទ្ធិរបស់តុលាការជាន់ដំបូង។ អង្គបុរេជំនុំជម្រះ ឬ តុលាការ ICTY មិនអាចគាំទ្រគំនិតដែលថា តុលាការជាន់ខ្ពស់ អាចសម្រេចក្រៅវិសាលភាពនៃបណ្តឹងសាទុក្ខបាននោះទេ។

៥៤. យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូល (ចៅក្រម Motoo NOGUCHI នឹងចេញមតិជំទាស់) ឯកភាពជាមួយជនជាប់ចោទថា អង្គជំនុំជម្រះសាលាដំបូង មិនបានផ្តល់សំអាងហេតុដែលមានលក្ខណៈរឹងមាំ ក្នុងការសម្រេចរក្សាទុកជនជាប់ចោទក្នុងឃុំបណ្តោះអាសន្ន ដោយអនុលោមតាមវិធាន៦៣(៣)(ខ)(៣)នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះតុលាការកំពូល (ចៅក្រម Motoo NOGUCHI នឹងចេញមតិជំទាស់) យល់ឃើញថា មូលដ្ឋានផ្លូវច្បាប់សំរាប់ការរក្សាទុកជនជាប់ចោទក្នុងឃុំបណ្តោះអាសន្ន នៅតែមានសុពលភាព។ ភាពស្របច្បាប់ក្នុងការរក្សាទុកជនជាប់ចោទក្នុងបណ្តោះអាសន្ន ត្រូវផ្អែកលើគោលការណ៍នៃការសន្មត់ទុកជាមុនដែលកើតចេញពីវិធាន៨២(១)នៃវិធានផ្ទៃក្នុង។ សំអាងហេតុនេះ មិនជាប់ពាក់ព័ន្ធនឹងហានិភ័យដែលជនជាប់ចោទរត់គេចខ្លួនក្នុងករណីការផ្តន្ទាទោសធ្ងន់ធ្ងរ ប៉ុន្តែជាប់ពាក់ព័ន្ធនឹងហានិភ័យដែលជនជាប់ចោទ នឹងមិនអាចមានវត្តមាននៅក្នុងដំណាក់កាលជំនុំជម្រះ។ អង្គហេតុដែលមាននៅក្នុងសំណុំរឿង បង្ហាញថាការជំនុំជម្រះក្នុងសំណុំរឿងលេខ០០២ គឺជាកិច្ចការដែលត្រូវត្រៀមរៀបចំយ៉ាងធំធាង និងភស្តុភារយ៉ាងច្រើនដែលទាក់ទងនឹងជនជាប់ចោទទាំងបួនរូបដែលអ្នកទាំងនោះភាគច្រើនមានបញ្ហាសុខភាព និងមានដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងច្រើនសន្ធឹកសន្ធាប់ និងក្រុមមេធាវីជាច្រើននាក់។ សូម្បីតែ ករណីតែមួយគត់ដែល ជនជាប់ចោទ ខកខានមិនអាចបង្ហាញខ្លួននៅចំពោះមុខតុលាការ អាចនឹងធ្វើឱ្យមហន្តរាយដល់លទ្ធភាពនៃការចេញសាលក្រម ក្នុង

[78] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខទៅនឹងដីកាសម្រេចលើសំណើសុំស្នើភស្តុតាងដោះបន្ទុកក្នុង Shared Material Drive D164/3/6 នៃថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ២៥។

រយៈពេលវេលាសមស្រប។ គោលបំណងនៃកិច្ចដំណើរនីតិវិធីឱ្យបានឆាប់រហ័ស អាចនឹងត្រូវបានធ្វើឱ្យរាំងស្ទះដោយងាយស្រួល ប្រសិនបើជនជាប់ចោទ លាក់ខ្លួន សម្រេចចិត្តមិនគោរពតាមដីកាកោះ ឬ ក៏អាចនឹងត្រូវបានរារាំងជាបណ្ដោះអាសន្នមិនឱ្យចូលរួមក្នុងសវនាការ។ នៅពេលដែលអង្គហេតុ ដែលសហព្រះរាជអាជ្ញាបានលើកឡើង នៅក្នុងសារណាតបរបស់ខ្លួន[79] អាចនឹងមិនត្រូវបានយកមកប្រើប្រាស់ដើម្បីអះអាងអំពីលក្ខខណ្ឌបន្ថែមសំរាប់រក្សាទុកជនជាប់ចោទក្នុងឃុំបណ្ដោះអាសន្ន ទោះបីជាយ៉ាងណាក៏ដោយ អង្គហេតុទាំងនេះ បានបង្ហាញយ៉ាងច្បាស់លាស់នៅក្នុងសេចក្ដីសម្រេចមុនៗ[80] ហើយ គាំទ្រលទ្ធភាពដែលជនជាប់ចោទមិនអាចចូលរួមក្នុងដំណើរការនីតិវិធីបាន ដោយសារការប៉ះពាល់នៃសណ្ដាប់ធ្នាប់សាធារណៈ ឬ ការវាយប្រហារលើបុគ្គល ឬ កង្វះនូវការថែទាំផ្នែកវិជ្ជសាស្ត្រត្រឹមត្រូវ ក្នុងករណីចាំបាច់។ បន្ទាប់ពីធ្វើការពិនិត្យយ៉ាងត្រឹមត្រូវលើកត្តានិងអង្គហេតុដែលជាប់ពាក់ព័ន្ធទាំងអស់ ដែលលើកឡើងជាភស្តុតាងនៅក្នុងវិវាទតទល់គ្នា អង្គជំនុំជម្រះសាលាដំបូង ត្រូវតែវាយតម្លៃថាតើហានិភ័យទាំងនេះនឹងអាចកាត់បន្ថយបានក្នុងកម្រិតណា តាមរយៈវិធានការដែលមិនមានមូលដ្ឋាននៅក្នុងការរក្សាទុកជនជាប់ចោទក្នុងឃុំបណ្ដោះអាសន្ន។

## ៤.៦ ទឡ្ហីករណ៍ទីបីនៃបណ្ដឹងសាទុក្ខ

៥៥. ទាក់ទងទៅនឹងផ្នែកទីមួយនៃទឡ្ហីករណ៍ទីបីនៃបណ្ដឹងសាទុក្ខរបស់ជនជាប់ចោទ អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថាអង្គជំនុំជម្រះសាលាដំបូង បានទទួលស្គាល់ការខកខានមិនបានផ្ដល់ជូនដល់ភាគីរួមទាំងជនជាប់ចោទនូវការជូនដំណឹងគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំសារណាទាក់ទីននឹងវិធាន៦៣(៣)។ ចំពោះទំរង់នៃសំណង សំរាប់ការខ្វះខាតក្នុងការជូនដំណឹងដល់ភាគី អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា ជនជាប់ចោទមិនត្រូវបានតម្រូវ ឱ្យលើកឡើងអំពីការ

[79] មើលខាងលើ កថាខណ្ឌ១៦។

[80] មើល ឧទាហរណ៍ សេចក្ដីសម្រេចស្ដីពីបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាបដិសេធសំណើសុំដោះលែង និងពន្យារពេលនៃដីកាឃុំខ្លួនជាបណ្ដោះអាសន្ន(អង្គបុរេជំនុំជម្រះ) C26/5/26 ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ កថាខណ្ឌ៥៣-៥៨, ៦៣,សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ( អង្គបុរេជំនុំជម្រះ) C26/9/12 ថ្ងៃ៣០ ខែមេសា ឆ្នាំ២០១០, កថាខណ្ឌ ៣៤ ៣៥ ៣៨ ៣៩ និងសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ(អង្គបុរេជំនុំជម្រះ) D427/4/15 ថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ កថាខណ្ឌ២៩។



E.C.C.C * C.E.T.C SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME

ប្រែប្រួលនៃស្ថានភាពដូចមានចែងក្នុងវិធាន៨២(៤)នៃវិធានផ្ទៃក្នុងឡើយ ហើយជនជាប់ចោទ គួរដាក់សំណើសុំឲ្យដោះលែងជាថ្មីមកកាន់អង្គជំនុំជម្រះសាលាដំបូង[81]។ ការអះអាងរបស់ជនជាប់ចោទដែលថា ប្រសិនបើមានការជូនដំណឹងជាមុនពីអង្គជំនុំជំនុំជម្រះ ជនជាប់ចោទ "ប្រហែលជាអាចពង្រីក និងពង្រឹងទឡ្ហីករណ៍នានានៅពេលសវនាការ"[82] គឺមិនបានបង្ហាញអំពីព្យសនកម្មណាមួយដែលមិនអាចត្រូវបានផ្តល់សំណងដោយអង្គជំនុំជម្រះសាលាដំបូងឡើយ។

៥៦. ទាក់ទងទៅនឹងផ្នែកទីពីរនៃទឡ្ហីករណ៍ទីបីនៃបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ ដូចដែលបានពន្យល់ខាងលើក្នុងកថាខណ្ឌ៣៨-៣៩ រួចហើយ គោលការណ៍ជាសារវន្តដែលគ្រប់គ្រងការឃុំខ្លួនបណ្តោះអាសន្ននៅមុនដំណាក់កាលជំនុំជម្រះ គឺជាគោលការណ៍នៃការសន្មត់ទុកជាមុនជាប្រយោជន៍ដល់ការដោះលែង ។ ហេតុដូច្នេះ តុលាការដែលវាយតម្លៃអំពីនីត្យានុកូលភាពនៃការឃុំខ្លួនបណ្តោះអាសន្ន ត្រូវតែវាយតម្លៃរាល់មូលហេតុ ដែលធានាការឃុំខ្លួន ហើយធ្វើការថ្លឹងថ្លែងអំពីហេតុផលនេះជាមួយនឹងសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានសេរីភាពបុគ្គល។ ដូចដែល តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្សបានសម្រេចរួចហើយ ការបន្តរក្សាទុកជនជាប់ចោទក្នុងឃុំបណ្តោះអាសន្ន អាចត្រូវបានផ្តល់យុត្តិកម្ម តែដរាបណាមាន"ការចង្អុលបង្ហាញជាក់លាក់អំពីផលប្រយោជន៍សាធារណៈពិតៗ..." ដែលត្រូវមានអត្ថប្រយោជន៍ច្រើនជាងការសន្មត់ទុកជាមុននៃសេរីភាព[83]។ ផ្អែកតាមការបញ្ជាក់ខាងលើ ក្នុងការបង្ហាញនូវហានិភ័យទូទៅនៃការរត់គេចខ្លួន ឬ ការរាំងស្ទះដល់ដំណើរការនីតិវិធី មិនមានលក្ខណៈគ្រប់គ្រាន់នោះទេ ប្រសិនបើ មិនបានសំអាងលើកាលៈទេសៈជាក់លាក់នៃរឿងក្តីនេះ ដែលហាមឃាត់ការដោះលែង ទោះបីដាក់ក្រោមលក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ក៏ដោយ[84]។

---

[81] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ៤២។

[82] សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ២៦។

[83] McKay តទល់ ចក្រភពអង់គ្លេស កថាខណ្ឌ៤២ ។

[84] សូមមើល ECHR, Boicenco តទល់ Moldova, កថាខណ្ឌ១៤៣ គណៈកម្មាធិការសិទ្ធិមនុស្ស, CCPR/C/94/D/1178/2003 Communication No. 1178/2003, Smantser តទល់ Belarus, នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៨, កថាខណ្ឌ[illegible]។ ជនជាប់ចោទ លើកឡើងថា "ដូចតុលាការកំពូលរបស់បារាំង, អង្គជំនុំជម្រះតុលាការកំពូល គប្បីបដិសេធ[illegible] [អង្គជំនុំជម្រះសាលាដំបូងរបស់អ.វ.ត.ក] ដែលចៅក្រម [នៃអង្គជំនុំជម្រះសាលាដំបូង[illegible]របស់អ.វ.ត.ក[illegible]

៥៧. ទោះបីជាយ៉ាងណាក៏ដោយ ដូចដែលតុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្សបានសម្រេចរួចហើយ កាតព្វកិច្ចដែលចងតុលាការ មិនមានន័យថាជាករណីយកិច្ចរបស់តុលាការជាន់ខ្ពស់ក្នុងការត្រួតពិនិត្យលើការលើកឡើងទាំងអស់ដែលមានក្នុងសារណារបស់ជនជាប់ចោទនោះទេ ប៉ុន្តែ ទាមទារឱ្យតុលាការដោះស្រាយ "រាល់អង្គហេតុជាក់ស្តែង"នានា ដែលបានលើកឡើងក្នុងសារណាទាំងនោះ[85]។ ជាពិសេស ដូចដែលមានចែងក្នុងវិធាន ៨២(១) និង(២)នៃវិធានផ្ទៃក្នុង ក្នុងការបង្ហាញភស្តុតាងអំពីស្ថានភាព និងលក្ខខណ្ឌជាក់លាក់ដែលភ្ជាប់ទៅនឹងការត្រួតពិនិត្យតាមផ្លូវតុលាការ គឺជាបន្ទុករបស់ជនជាប់ចោទ។ បន្ទាប់មក គឺជាកាតព្វកិច្ចរបស់តុលាការក្នុងការវាយតម្លៃលើភាពគ្រប់គ្រាន់នៃការដោះលែង ដោយដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ប៉ុណ្ណោះ។ ការបែងចែកបន្ទុកនេះ គឺស្របជាមួយនឹងយុត្តិសាស្ត្ររបស់តុលាការ ICTY[86]។

៥៨. ជនជាប់ចោទ ស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលបដិសេធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចោល ពីព្រោះអង្គជំនុំជម្រះសាលាដំបូង ខកខានមិនបានពិចារណាអំពីការដោះលែងដោយដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ នៅពេលដែលកត់សំគាល់ថា អង្គជំនុំ

---

បន្តរក្សាទុកក្នុងឃុំជាបណ្តោះអាសន្នដោយឥតបញ្ជាក់ពីមូលហេតុម្តេចបានជាការដាក់ត្រួតពិនិត្យតាមផ្លូវតុលាការ គ្មានការធានាគ្រប់គ្រាន់នោះឡើយ ហើយដោយឥតផ្តល់មូលហេតុចំពោះការសម្រេចសេចក្តីរបស់ខ្លួនឡើយ"។ (សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ៣៥)។ នៅក្នុងសេចក្តីសម្រេចដែលជនជាប់ចោទបានយោងលើ តុលាការកំពូលរបស់បារាំង បដិសេធសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះនៃតុលាការឧទ្ធរណ៍ Nimes ចោល ពីព្រោះ តុលាការនេះ បានរំលោភបំពានលើច្បាប់ក្នុងស្រុកដោយខកខានមិនបានផ្តល់នូវសំអាងហេតុផ្នែកអង្គច្បាប់និងផ្នែកអង្គហេតុថាមូលហេតុដូចម្តេចបានជាការត្រួតពិនិត្យតាមផ្លូវតុលាការ គ្មានការធានាគ្រប់គ្រាន់ (ការបែងចែកព្រហ្មទណ្ឌសំណុំរឿងឧទ្ធរណ៍លេខ ៩៧៨៣០១៤ នៃថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៧)។ សេចក្តីសម្រេចនេះ មិនជាប់ពាក់ព័ន្ធទៅនឹងវិធាន៨២(១)នៃវិធានផ្ទៃក្នុងឡើយ។

[85] Nikolova តទល់ Bulgaria កថាខណ្ឌ៦១។

[86] "ម្ចាស់បណ្តឹងឧទ្ធរណ៍ តម្រូវឱ្យបង្ហាញដល់អង្គជំនុំជម្រះសាលាដំបូង ថាមានវិធានការសុវត្ថិភាពគ្រប់គ្រាន់ ក្នុងការបង្ហាញ ថាគ្មានហានិភ័យក្នុងការរត់គេចខ្លួន"(តុលាការ ICTY, សំណុំរឿងលេខ IT-05-88-AR65.7, សេចក្តីសម្រេចលើបណ្តឹងរបៀងរបស់ Vujadin Popovic ប្រឆាំងនឹងសេចក្តីសម្រេចលើសំណើរបស់ Popovic សុំដោះលែងបណ្តោះអាសន្ន នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៨ កថាខណ្ឌ ១៧ , មើល តុលាការ ICTY Stanisic និង Simatovic IT-03-69-PT សេចក្តីសម្រេចលើសំណើសុំដោះលែងជាបណ្តោះអាសន្ន នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៨ កថាខណ្ឌ ៣៧)។

00702762



ជម្រះសាលាដំបូង ប្រហែលជាបានធ្វើការស៊ើបអង្កេតឱ្យបានស៊ីជម្រៅនូវ វិធានការជម្រើសផ្សេងក្រៅពីការឃុំខ្លួនបណ្តោះអាសន្នដែលអាចធានាបានដូចគ្នានូវវត្តមានរបស់ជនជាប់ចោទនៅដំណាក់កាលជំនុំជម្រះ សេចក្តីសម្រេចនេះ នៅតែមានសុពលភាព ដោយហេតុថាសារណាផ្ទាល់មាត់ និងលាយលក្ខណ៍អក្សររបស់ជនជាប់ចោទ មិនបានផ្តល់នូវសេចក្តីលម្អិតដែលទាក់ទិននឹងមធ្យោបាយធានាវត្តមាននេះទេ[87]។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល បដិសេធផ្នែកទឡ្ហីករណ៍ទីបីរបស់ជនជាប់ចោទចោលជាអសារបង់។

## ៥. ផ្នែកសម្រេចសេចក្តី

**យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលសម្រេច:**

**កែប្រែ**សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយអនុលោមតាមកថាខណ្ឌ ៣៧ខាងលើ

**កែប្រែ** (ចៅក្រម Motoo NOGUCHI នឹងចេញមតិជំទាស់) សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដោយអនុលោមតាមកថាខណ្ឌ៥៤ខាងលើ និង

**បដិសេធ**ផ្នែកដទៃទៀតនៃបណ្តឹងសាទុក្ខភ្លាមៗរបស់ជនជាប់ចោទ ចោលជាអសារបង់។

មតិជំទាស់របស់ចៅក្រម Motoo NOGUCHI នឹងត្រូវចេញតាមក្រោយ។

**រាជធានីភ្នំពេញ ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១១**
**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ឹម**

[87] ប្រតិចារិក នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១ ទំព័រ៧៩ ជួរទី២១ និងទំព័រ៨៣ ជួរទី១ (ភាសាអង់គ្លេស) (ស សូវាន)។